ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

PHNOM PENH WATER SUPPLY AUTHORITY

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ



# របាយការណ៍ប្រចាំ ត្រីមាសទី៤ ឆ្នាំ២០១៨



## គោលដៅយុទ្ធសាស្ត្រចម្បង របស់ រ.ទ.ស.ភ. មានដូចខាងក្រោម៖

ពង្រីកការផ្គត់ផ្គង់ទឹកទៅតំបន់ជុំវិញរាជធានីភ្នំពេញ ដោយរក្សាអត្រា និងស្តង់ដារដូចគ្នា នៅក្នុងរាជធានីភ្នំពេញ។ វិភាគថ្លៃដើម និងកំណែទម្រង់ដំណើរការ និងបែបបទដើម្បីកាត់បន្ថយថ្លៃដើមទឹក បង្កើនប្រសិទ្ធភាពបុគ្គលិក និងបន្តកសាងសមត្ថភាពរបស់សហគ្រាស។ តាំងចិត្តខ្ពស់ ចំពោះការទទួលខុសត្រូវដល់សង្គម និងបរិស្ថាន។ ប្រៀបធៀបបែបយុទ្ធសាស្ត្រ ជាមួយបណ្តាអង្គភាពទឹកស្អាតនានា ដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក។


លេខ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ: ៨៥៥(0)២៣៧២៤០៤៦
លេខទូរសារ: ៨៥៥(0)២៣៤២៧៦៥៧

អ៊ីម៉ែល:
ir@ppwsa.com.kh

# មាតិកា


១- ព័ត៌មានទូទៅអំពីរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ១

២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ២

ក- លទ្ធផលការងារប្រព្រឹត្តកម្ម ប្រព័ន្ធចែកចាយទឹក និងការងារកាត់បន្ថយទឹកបាត់បង់ ២

ក.១- លទ្ធផលការងារប្រព្រឹត្តកម្ម ២

ក.២- លទ្ធផលការងាររៀបចំ ប្រព័ន្ធចែកចាយទឹកស្អាត ៣

ក.៣- លទ្ធផលការងារកាត់បន្ថយទឹកបាត់បង់ ៤

ខ- សកម្មភាព និងលទ្ធផលការងារអាជីវកម្ម ៥

ខ.១- ការងារផ្គត់ផ្គង់ទឹកស្អាត ជូនប្រជាពលរដ្ឋមានចំណូលទាប ៥

ខ.២- ការងារតបណ្តាញចូលផ្ទះ និងការគ្រប់គ្រងអតិថិជន ៦

គ- ការងារគ្រប់គ្រងធនធានមនុស្ស ៧

គ.១- ការអនុវត្តន៍លក្ខន្តិកៈបុគ្គលិក និងបទបញ្ជាផ្ទៃក្នុង ៧

គ.២- កម្រិតជំនាញរបស់មន្ត្រី និយោជិត ៧

៣- សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ៨

៤- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ ១១

- សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល ១៤
- របាយការណ៍នៃការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ១៥
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេប ១៦
- របាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗសង្ខេប ១៨
- របាយការណ៍បម្រែបម្រួលមូលធនសង្ខេប ១៩
- របាយការណ៍លំហូរសាច់ប្រាក់សង្ខេប ២០
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ ២២

៥- ព័តមានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន ៤០

ហត្ថលេខារបស់អភិបាល រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ៤១




# ១- ព័ត៌មានទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ.)

## PHNOM PENH WATER SUPPLY AUTHORITY (PPWSA)

- អក្សរកូដ: KH1000010004
- អាសយដ្ឋាន: អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- លេខទូរស័ព្ទ: +៨៥៥(០)២៣ ៦៣៥ ៨០ ៨០ / ៧២៤ ០៤៦
- លេខទូរសារ: +៨៥៥(០)២៣ ៤២៧ ៦៥៧
- គេហទំព័រ: www.ppwsa.com.kh អ៊ីម៉ែល: ir@ppwsa.com.kh
- លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម: Co.0៨៣៩Et/២០១២
  កាលបរិច្ឆេទ: ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២
- លេខអាជ្ញាបណ្ណអាជីវកម្ម: អនុក្រឹត្យលេខ ៥២ អនក្រ.បក
  កាលបរិច្ឆេទ: ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦
- សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន លេខ: ០១២/១២ គ.ម.ក/ស.ស.រ.
  កាលបរិច្ឆេទ: ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២
- ឈ្មោះបុគ្គលតំណាង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ: **ឯកឧត្តម ស៊ឹម ស៊ីថា**



## ២- ព័ត៌មានលទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

### ក- លទ្ធផលការងារប្រព្រឹត្តកម្ម ប្រព័ន្ធចែកចាយទឹក និងការងារកាត់បន្ថយទឹកបាត់បង់

### ក.១- លទ្ធផលការងារប្រព្រឹត្តកម្ម

ក្នុងរយៈពេលពេញមួយត្រីមាសកន្លងទៅនេះ រ.ទ.ស.ភ. បានបន្តធានាផ្គត់ផ្គង់ទឹកស្អាតស្របទៅតាមតម្រូវការប្រើប្រាស់របស់អតិថិជនដោយធានាទាំងបរិមាណ និងគុណភាពទឹកស្អាតគ្មានមេរោគ ព្រមទាំងអាចផឹកបានពីបណ្តាញដោយផ្ទាល់។ រោងចក្រភូមិព្រៃក បានផលិតទឹកស្អាតលើសផែនការប្រមាណជា១% កត្តានេះបណ្តាលមកពីកំណើននៃការប្រើប្រាស់របស់អតិថិជនមានការកើនឡើង។ ជាមួយគ្នានេះដែរ រោងចក្រជ្រោយចង្វារបានផលិតទឹកលើសផែនការប្រមាណ ៦% ព្រោះក្នុងត្រីមាសទី៤នេះ យើងទទួលរងអាកាសធាតុក្តៅឡើងខ្លាំងជាងបណ្តាឆ្នាំកន្លងទៅ ដែលធ្វើឲ្យយើងត្រូវបង្កើនការបូមច្រើនជាងមុនដើម្បីបំពេញ តាមតម្រូវការប្រើប្រាស់ជាក់ស្តែងរបស់ប្រជាពលរដ្ឋ និងកំណើននៃការរីកដុះដាលនៅតំបន់ប៉ែកខាងលិច និងខាងជើងនៃរាជធានីភ្នំពេញ។ រីឯរោងចក្រផលិតទឹកស្អាតនិរោធបានខិតខំបំពេញ ការផលិតរបស់ខ្លួនស្មើរតែ១០០% តាមផែនការដែលបានគ្រោងទុក ព្រោះដើម្បីបំពេញតាមតម្រូវការនៃការប្រើប្រាស់កើនឡើងខ្លាំងក្នុងរដូវប្រាំងនេះ។

ជារួមលទ្ធផលជាក់ស្តែងការងារផលិតកម្ម និងលទ្ធផលនៃការពិនិត្យគុណភាពទឹក ក្នុងត្រីមាសទី៤ ឆ្នាំ២០១៨ ដូចមានក្នុងតារាងខាងក្រោម៖

| **បរិយាយ** | **ផែនការ** (គិតជា ម៉ែត្រគូប) | **អនុវត្តជាក់ស្តែង** (គិតជា ម៉ែត្រគូប) | **អត្រា** (គិតជា %) |
|---|---|---|---|
| រោងចក្រ ភូមិព្រៃក | ១៤.៨៧៤.០០០ | ១៤.៩៧៤.៩៩៧ | ១០១ |
| រោងចក្រ ជ្រោយចង្វារ | ១៣.៩២៣.០០០ | ១៤.៦៩៣.៨២០ | ១០៦ |
| រោងចក្រ និរោធ | ២៣.៨៩៩.៥៥៧ | ២៣.៧៩១.៤៨២ | ៩៩,៥៤ |
| **សរុប** | ៥២.៦៩៦.៥៥៧ | ៥៣.៤៦០.២៩៩ | ១០១ |

ត្រួតពិនិត្យគុណភាពទឹកតាមរោងចក្រផលិតទឹកទាំងបួនចំនួន ៣ដង/ថ្ងៃ ត្រួតពិនិត្យគុណភាពទឹកនៅតាមបណ្តាញចែកចាយចំនួន ៨០កន្លែង/សប្តាហ៍ យ៉ាងទៀតទាត់ គុណភាពទឹកស្ថិតក្នុងកម្រិតអនុញ្ញាតរបស់ស្តង់ដារគុណភាពទឹកផឹកថ្នាក់ជាតិ។ ការងារត្រួតពិនិត្យ គុណភាពទឹក ទាំងនៅតាមរោងចក្រ និងតាមបណ្តាញចែកចាយតាមយន្តការ និងកម្មវិធីមានស្រាប់បានជាប់-លាប់ និងទៀងទាត់ ដោយធានាបាននូវគុណភាពទឹកគ្មានមេរោគ និងផឹកបានដោយផ្ទាល់ពីបណ្តាញ ស្របតាមស្តង់ដារទឹកផឹករបស់អង្គការសុខភាពពិភពលោក។

| មុខវិភាគ | ឯកតា | WHO | រោងចក្រ ភូមិព្រៃក | រោងចក្រ ជ្រោយចង្វារ | រោងចក្រ និរោធ | បណ្តាញចែកចាយ |
|---|---|---|---|---|---|---|
| **ភាពល្អក់** | NTU | ≤ ៥ | ០,៥៣ | ០,៦៥ | ០,៥០ | ០,៦៦ |
| **តម្លៃប៉េហាស់** | pH | ៦,៥ - ៨,៥ | ៧,២៥ | ៧,៥៧ | ៧,១៩ | ៧,៥៥ |
| **ក្លរសេរី** | mg/l | ០,១ - ១ | ១,១៣ | ០,៨២ | ០,៩៤ | ០,១៧ |
| **ក្លរសរុប** | mg/l | < ២ | ១,៣៤ | ០,៩៤ | ១,១១ | ០,២៦ |
| **មេរោគកូលីហ្វម** | cfu/100ml | 0 | 0 | 0 | 0 | 0 |
| **មេរោគអ៊ីកូលី** | cfu/100ml | 0 | 0 | 0 | 0 | 0 |

## ២- ព័ត៌មានលទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក (ត)

### ក- លទ្ធផលការងារប្រព្រឹត្តកម្ម ប្រព័ន្ធចែកចាយទឹក និងការងារកាត់បន្ថយទឹកបាត់បង់ (ត)

### ក.២- លទ្ធផលការងាររៀបចំ ប្រព័ន្ធចែកចាយទឹកស្អាត

| **បរិយាយ** | **អនុវត្តជាក់ស្តែង** (គិតជាម៉ែត្រ) |
|---|---|
| ១- ខណ្ឌដូនពេញ | ២.៧៩៦,៣០ |
| ២- ខណ្ឌ៧មករា | - |
| ៣- ខណ្ឌចំការមន | ៥៣,៨០ |
| ៤- ខណ្ឌឫស្សីកែវ | ៣.៩៤៩,៤៥ |
| ៥- ខណ្ឌមានជ័យ | ១.៩៤៦,២០ |
| ៦- ខណ្ឌដង្កោ | ២.៥៣០,៤៥ |
| ៧- ខណ្ឌខណ្ឌពោធិ៍សែនជ័យ | ១០.៦៤៩,១០ |
| ៨- ខណ្ឌសែនសុខ | ៥.៨០១,៤០ |
| ៩- ខណ្ឌជ្រោយចង្វារ | ១.៥៣៩,០៥ |
| ១០- ខណ្ឌច្បារអំពៅ | ៧.៨០០,៧០ |
| ១១- ខណ្ឌព្រែកព្នៅ | ៦៤៩,១០ |
| ១២- ក្រុងតាខ្មៅ | ៧៦៣,០០ |
| **សរុប** | **៣៨.៤៧៨,៥៥** |





ប្រវែងបំពង់ដែលបានដាក់តាមឆ្នាំនីមួយៗ
(គិតជាគីឡូម៉ែត្រ)



## ២- ព័ត៌មានលទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក (ត)

### ក- លទ្ធផលការងារប្រព្រឹត្តកម្ម ប្រព័ន្ធចែកចាយទឹក និងការងារកាត់បន្ថយទឹកបាត់បង់ (ត)

### ក.៣- លទ្ធផលការងារកាត់បន្ថយទឹកបាត់បង់

អត្រាទឹកបាត់បង់របស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅត្រីមាសទី៤ ឆ្នាំ២០១៨ មានកម្រិតនៅក្នុងរង្វង់លេខមួយខ្ទង់ប៉ុណ្ណោះ ពោលគឺរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានបន្ថយទឹកបាត់បង់មកនៅត្រឹមអត្រា៧,៩៤% ដូចបានបង្ហាញក្នុងក្រាហ្វិចខាងក្រោម។

ក្រាហ្វិចបង្ហាញពីអត្រាទឹកបាត់បង់ពីឆ្នាំ២០០៣ ដល់ត្រីមាសទី៤ ឆ្នាំ២០១៨ (គិតជាភាគរយ)






# ២- ព័ត៌មានលទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក (ត)

## ខ- សកម្មភាព និងលទ្ធផលការងារអាជីវកម្ម

## ខ.១- ការងារផ្គត់ផ្គង់ទឹកស្អាត ជូនប្រជាពលរដ្ឋមានចំណូលទាប

បើគិតចាប់ពីពេលអនុវត្តកម្មវិធី "ផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋមានចំណូលទាប" រហូតដល់ចុងត្រីមាសទី៤ ឆ្នាំ២០១៨នេះ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋមានចំណូលទាបសរុប ៣៤.៩២៦បណ្តាញ។ ក្នុងត្រីមាសនេះបានឧបត្ថម្ភធនសរុបចំនួន១០៣បណ្តាញ ដែល រ.ទ.ស.ភ. ត្រូវចំណាយទឹកប្រាក់សរុប ៦.១១៦.៦៦២.៧៦០រៀល ស្មើនឹង ១.៥២៩.១៦៦ដុល្លាអាមេរិក។

បណ្តាញអតិថិជនមានចំណូលទាប ក្នុងគ្រាតាមបណ្តាឆ្នាំនីមួយៗ




## ការវាយតម្លៃ

ការផ្តល់សេវាទឹកស្អាតដល់ប្រជាពលរដ្ឋមានចំណូលទាប ពិសេសប្រជាពលរដ្ឋក្រីក្ររស់នៅមានលក្ខណៈ ប្រមូលផ្តុំក្នុងសហគមន៍ដែលកន្លងមកមិនធ្លាប់បានទទួលទឹកស្អាតប្រើប្រាស់ផ្ទាល់ពីរដ្ឋ ក្នុងតម្លៃមួយ សមស្របថោកជាងឯកជន ផ្គត់ផ្គង់២៤ម៉ោងក្នុង១ថ្ងៃ ៧ថ្ងៃក្នុង១សប្តាហ៍ ធានានូវគុណភាពហូបបានផ្ទាល់ពីក្បាលម៉ាស៊ីន និងមានការឧបត្ថម្ភធនផងនោះ បានធ្វើឲ្យប្រជាពលរដ្ឋមានចំណូលទាប សប្បាយរីករាយ និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល និងម្ចាស់ជំនួយ ដែលបានយកចិត្តទុកដាក់ចំពោះជីវភាពរស់នៅរបស់ពួកគាត់។

| **តបណ្តាញជូនប្រជាពលរដ្ឋមានចំណូលទាប** | | **សរុប** (គ្រួសារ) | **ក្នុងក្រុង** (គ្រួសារ) | **ជាយក្រុង** (គ្រួសារ) |
|---|---|---|---|---|
| | បង់រំលស់ ១២ខែ | - | - | - |
| ឧបត្ថម្ភធន ៣០% | និង បង់រំលស់ ១២ខែ | - | - | - |
| ឧបត្ថម្ភធន ៥០% | និង បង់រំលស់ ១២ខែ | ៤៦ | - | ៤៦ |
| ឧបត្ថម្ភធន ៧០% | និង បង់រំលស់ ១២ខែ | ១៤ | - | ១៤ |
| ឧបត្ថម្ភធន ១០០% | និង បង់រំលស់ ០៤ខែ | ៤៣ | - | ៤៣ |
| សរុប | | ១០៣ | - | ១០៣ |

# ២- ព័ត៌មានលទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក (ត)

## ខ- សកម្មភាព និងលទ្ធផលការងារអាជីវកម្ម (ត)

## ខ.២- ការងារតបណ្តាញចូលផ្ទះ និងការគ្រប់គ្រងអតិថិជន

### - ការងារតបណ្តាញចូលផ្ទះ

ការងារតបណ្តាញចូលផ្ទះ ត្រូវអនុវត្តតាមបែបបទដំណើរការតាមស្តង់ដារមួយដែលមានលក្ខណៈសាមញ្ញ និងងាយអនុវត្ត ទាំងមន្ត្រី-និយោជិតរបស់ រ.ទ.ស.ភ. និងអតិថិជន។ គោលបំណងរបស់ រ.ទ.ស.ភ. គឺជួយសម្រួលប្រជាពលរដ្ឋ ក្នុងការបំពេញបែបបទ តបណ្តាញទឹកឲ្យបានលឿន ទទួលប្រាក់ថ្លៃទឹកនៅនឹងកន្លែង កាត់បន្ថយការចំណាយលើការធ្វើដំណើររបស់ប្រជាពលរដ្ឋ។

### - ការងារគ្រប់គ្រងអតិថិជន

យើងគ្រប់គ្រងអតិថិជនបានល្អ និងមានប្រសិទ្ធភាពដោយ ៖

- បញ្ចូលទិន្នន័យអតិថិជនតបណ្តាញថ្មី និងទិន្នន័យនាឡិកាប្តូរថ្មីទៅក្នុងប្រព័ន្ធបានត្រឹមត្រូវ និងទាន់ពេលវេលា " **មិនលើសពីបីថ្ងៃការងារក្រោយថ្ងៃតបណ្តាញ និងប្តូរនាឡិការួច** " ។
- បញ្ចូលរាល់សំណើកែតម្រូវទិន្នន័យអតិថិជនទៅក្នុងប្រព័ន្ធទាន់ពេលវេលា ។
- ធ្វើ Back Up ទុករាល់ថ្ងៃ និងសប្តាហ៍ ទិន្នន័យអតិថិជននៅក្នុងប្រព័ន្ធ ដើម្បីធានាសុវត្ថិភាពដោយធ្វើការត្រួតពិនិត្យនៅរាល់ចុងត្រីមាសទៀតផង ។
- ធ្វើការថែទាំកុំព្យូទ័រ និង Hardware ទូទាំងអង្គភាពតាមកម្មវិធីដែលបានកំណត់ ។

| **ប្រភេទអតិថិជន** | **២០១៤** | **២០១៥** | **២០១៦** | **២០១៧** | **ត្រីមាសទី៤ ២០១៨** |
|---|---|---|---|---|---|
| ជីវភាព | ២២៥.៧៣៥ | ២៣២.៣៣២ | ២៥១.០៦៧ | ២៧១.៣១៧ | ៣០១.៨៣៤ |
| អាជីវកម្ម | ៤៤.២៥៨ | ៥១.២៥៦ | ៥៤.២២៨ | ៥៥.៨៩១ | ៥៨.៧៨៩ |
| អង្គភាពរដ្ឋ | ៧៨៥ | ៧៩៦ | ៦៥៥ | ៦៥៥ | ៦៦៤ |
| អ្នកលក់ទឹក | ១៤ | ១៣ | ១១ | ០៨ | ០៧ |
| តំណាងចែកចាយ | ២០ | ២៤ | ២២ | ២០ | ២១ |
| Standpipe | - | - | - | - | ១៤ |
| បន្ទប់ជួល | ០ | ៤.៦០៣ | ៤.៨៥២ | ៥.៣៩៧ | ៥.៧០៣ |
| សរុប | ២៧០.៨១២ | ២៨៩.០២៤ | ៣១០.៨៣៥ | ៣៣៣.២៨៨ | ៣៦៧.០៣២ |

### ក្រាហ្វិចបង្ហាញពីបំណែងចែកអតិថិជន ចុងត្រីមាសទី៤ ឆ្នាំ២០១៨ (អតិថិជនសរុបចំនួន: ៣៦៧.០៣២អតិថិជន)



## ២- ព័ត៌មានលទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក (ត)

### គ- ការងារគ្រប់គ្រងធនធានមនុស្ស

ក្នុងត្រីមាសទី៤ នេះ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានមន្ត្រីនិយោជិតទាំងអស់ចំនួន ១.០៤៧រូប (នារី៖ ១៩០រូប) ក្នុងនោះមាន៖

- មន្ត្រីក្របខ័ណ្ឌរដ្ឋ ចំនួន០២រូប គឺអគ្គនាយក និងអគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ច និងផ្សារមូលបត្រ និងជាប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
- មន្ត្រី និយោជិតក្របខ័ណ្ឌសហគ្រាស ចំនួន ៩៩៦រូប (នារី៖១៨៥រូប)
- និយោជិតសាកល្បងការងារ ចំនួន ០៤រូប (នារី៖០១រូប)
- និយោជិតជាប់កិច្ចសន្យា ចំនួន ៤៥រូប (នារី៖០៤រូប)

### គ.១- ការអនុវត្តន៍លក្ខន្តិកៈបុគ្គលិក និងបទបញ្ជាផ្ទៃក្នុង

- ចំនួនបុគ្គលិកដែលបានប្រើប្រាស់ក្នុងរយៈកាលកន្លងមកក្នុងកម្រិត ២,៨៥ លើ ១.០០០ អតិថិជន (ចំនួនអតិថិជនសរុបចុងគ្រា ៣៦៧.០៣២)។
- ការអនុវត្តន៍តួនាទី ភារកិច្ច វិន័យ ការងារ ពេលម៉ោងធ្វើការ សំលៀកបំពាក់ និងការប្រើប្រាស់សម្ភារការពារសុវត្ថិភាពពលកម្ម របស់មន្ត្រី-និយោជិត កម្មករ កាន់តែប្រសើរ។

### គ.២- កម្រិតជំនាញរបស់មន្ត្រី និយោជិត



# ៣- សេចក្តីថ្លែងរបស់ ប្រធានក្រុមប្រឹក្សាភិបាល



**ឯកឧត្តម សឹម ណារ៉ា**
ប្រធានក្រុមប្រឹក្សាភិបាល

## ក្នុងត្រីមាសទី៤ ឆ្នាំ២០១៨ នេះ

"ដោយទទួលបានទំនុកចិត្តពីរាជរដ្ឋាភិបាល ជាមួយនឹងការឧបត្ថម្ភ គាំទ្រពីក្រសួងអាណាព្យាបាលទាំងពីរ រដ្ឋាករទឹកស្វយ័តក្រុង-ភ្នំពេញ បានបំពេញកាតព្វកិច្ចដោយជោគជ័យ គ្រប់សកម្មភាពធុរកិច្ចរបស់ខ្លួន។ យើងកំពុងបន្តអភិវឌ្ឍសេវាទឹកស្អាតជារៀងរាល់ថ្ងៃ ទាំងគុណភាព ទាំងបរិមាណ ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់របស់ប្រជាជននៃ ទីក្រុងភ្នំពេញ និងទីក្រុងតាខ្មៅ និងចូលរួមចំណែកក្នុងដំណើរការអភិវឌ្ឍន៍របស់ទីក្រុងទាំងពីរ។"

ក្នុងត្រីមាសនេះ រ.ទ.ស.ភ. បានទទួលចំណូលសរុប ៩១.២៤៦.៤១០.០០០រៀល និងប្រាក់ចំណេញមុនបង់ពន្ធលើប្រាក់-ចំណេញ៥៦.៤៥០.៣៨៤.០០០រៀល។ លទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិកមានចំនួន៤២.៥៨១.០៨២.០០០រៀល។ ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន( basic earnings per share ) គឺ៤៨៩,៥៩រៀល។

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ វិនិយោគ កសាង ពង្រីកដំណើរការ និងជួសជុលថែរក្សាមធ្យោបាយសម្រាប់ផលិត និងប្រព័ន្ធចែកចាយទឹកស្អាត និងអនាម័យ។ ប្រើប្រាស់នូវគ្រប់វិធានការដើម្បីបង្កើនផលិតកម្ម សេវាកម្ម និងធានាគុណភាពទឹកស្អាតឆ្លើយតបទៅនឹងតម្រូវការសម្រាប់ជីវភាពរស់នៅ អាជីវកម្ម-សេវាកម្ម និងឧស្សាហកម្ម។ ធ្វើអាជីវកម្ម សេវាកម្ម និងការងារផ្សេងៗទៀត ដែលទាក់ទងនឹងវិស័យទឹកស្អាត និងអនាម័យនៅក្នុង ឬក្រៅប្រទេស តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងដោយអនុលោម តាមច្បាប់។ សហប្រតិបត្តិការលើផ្នែកបច្ចេកទេស ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ជាមួយដៃគូរអភិវឌ្ឍន៍ ក្នុង និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ. ទៅតាមគោលនយោបាយ របស់រាជរដ្ឋាភិបាល។ ធានាឲ្យបាននូវចីរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុដោយផ្សារភ្ជាប់ជាមួយប្រយោជន៍សង្គម បង្កើនប្រសិទ្ធភាពបុគ្គលិក និងបន្តកសាងសមត្ថភាពរបស់សហគ្រាសវិភាគកត្តាថ្លៃដើម និងកំណែទម្រង់ដំណើរការ និងបែបបទដើម្បីកាត់បន្ថយថ្លៃដើមទឹក ប្រៀបធៀបបែបយុទ្ធសាស្ត្រជាមួយបណ្តាអង្គភាពទឹកស្អាតនានា ដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក។

## សេវាដ៏មានប្រសិទ្ធភាព

យើងនៅតែបន្តធានាការផ្គត់ផ្គង់ទឹកស្អាត២៤ម៉ោងលើ២៤ម៉ោង ជាមួយនឹងគុណភាព ដែលអាចទទួលទានបានដោយផ្ទាល់ពីក្បាលរ៉ូប៊ីណេ។ ក្នុងត្រីមាសទី៤ ឆ្នាំ២០១៨នេះ យើងផលិតបាន៥៣.៤៦០.២៩៩ម$^{៣}$។ ទន្ទឹមនេះយើងបានប្រើប៉ូលីអាលុយ-មីញ៉ូមក្លរ៉ាយ (PAC) ជំនួសសាច់ជូរវិញ ដើម្បីបង្កើនគុណភាពទឹក និងកាត់បន្ថយចំណាយលើសារធាតុគីមី។ ជាលទ្ធផលនៅក្នុងត្រីមាសនេះ កំណើនអតិថិជនក្នុងគ្រាបានកើនចំនួន ៥.៣១៦បណ្តាញ។ ក្នុងនោះកំណើនអតិថិជន ដែលមានចំណូលទាបចំនួន២៣៣បណ្តាញ ដែលយើងតែងយកចិត្តទុកដាក់ជាទៀងទាត់។ ជាមួយគ្នានេះយើងបានខិតខំយ៉ាងស្វិតស្វាញ ក្នុងការរក្សាអត្រាទឹកបាត់បង់ ដែលជាសូចនករដ៏សំខាន់ក្នុងវិស័យទឹកស្អាតឲ្យស្ថិតក្នុងកម្រិត លេខមួយខ្ទង់គឺ ៧,៩៤% ប្រសើរជាងគេក្នុងតំបន់អាស៊ី។

យើងបានផ្សព្វផ្សាយពីការងារផ្គត់ផ្គង់ទឹកស្អាតរបស់យើង ដែលយើងតែងធ្វើជាទៀងទាត់ ជូនដល់ប្រជាពលរដ្ឋក្នុងសហគមន៍បានជ្រាបហើយរាល់សំណើរផ្សេងៗ ដែលយើងបានទទួលពីអតិថិជនពាក់ព័ន្ធនឹងសេវាទឹកស្អាតត្រូវបានដោះស្រាយទាន់ពេលវេលាកំណត់។ បំពង់មេនាំទឹក និងបណ្តាញចែកចាយទឹកស្អាត ត្រូវបានពង្រីកជារៀងរាល់ថ្ងៃ បំពង់ប្រវែង ៣៨.៤៧៨,៥៥ម៉ែត្រត្រូវបានដាក់ក្នុងត្រីមាសទី៤ ឆ្នាំ២០១៨ នេះ។

## ការអនុវត្តន៍ការងាររបស់ក្រុមប្រឹក្សាភិបាល

### ១- លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសាមញ្ញ លើកទី៩ អាណត្តិទី៦ របស់ រ.ទ.ស.ភ. :

រ.ទ.ស.ភ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសាមញ្ញ លើកទី៩ អាណត្តិទី៦ កាលពីថ្ងៃសុក្រ ៦រោច ខែមិគសិរ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោង ៨:៣០នាទី នៅទីចាត់ការប្រតិបត្តិនៃ រ.ទ.ស.ភ.។ អង្គប្រជុំបានពិនិត្យ និងពិភាក្សាផ្លាស់ប្តូរយោបល់លើខ្លឹមសារលម្អិតនៃរបាយការណ៍ ដែលបង្ហាញដោយមន្ត្រីជំនាញ រ.ទ.ស.ភ ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម ៖

១. ឯកភាពទទួលជ្រាបជារបាយការណ៍ លើរបាយការណ៍ស្តីពី លទ្ធផលការងារសវនកម្មផ្ទៃក្នុង ត្រីមាសទី៤ ឆ្នាំ២០១៨ ដែលបានចុះសវនកម្មនៅអង្គភាពលទ្ធកម្ម និងនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ។

២. ឯកភាពទាំងស្រុងលើរបាយការណ៍លទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងត្រីមាសទី៤ ឆ្នាំ២០១៨ ដែលបានដេញថ្លៃ (១៣ករណី) ពិគ្រោះថ្លៃ០២ករណី ដែលមានទឹកប្រាក់សរុបចំនួន ១៩.៨៧៥.៧០៨.៣៩៩,៣៨រៀល។

៣. ឯកភាពទាំងស្រុងលើរបាយការណ៍លទ្ធផលប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គម អនុវត្តនៅក្នុងត្រីមាសទី៤ ឆ្នាំ២០១៨ ដែលបានប្រើប្រាស់ថវិកាមូលនិធិសរុបចំនួន ២.៧១៩.៦១៧.៣៥៦រៀល ស្មើនឹង៩៦% និងទឹកប្រាក់នៅសល់ ៨៧.៨១៣.២៩៤រៀល ស្មើនឹង៤% នៃមូលនិធិសរុប។

៤. ឯកភាពទាំងស្រុងលើរបាយការណ៍ស្តីពីលទ្ធផលការងារ១០ខែ បូក២ខែប៉ាន់ស្មានឆ្នាំ២០១៨ និងផែនការត្រីមាសទី១ ឆ្នាំ២០១៩។

៥. អនុម័តជាឯកច្ឆន្ទលើសំណើសុំពិនិត្យ-អនុម័តគោលការណ៍ សម្រាប់ត្រៀមអនុវត្តមហាសន្និបាតភាគហ៊ុនិកលើកទីដែលនឹងប្រព្រឹត្តទៅក្នុងត្រីមាសទី២ ឆ្នាំ២០១៩ ដោយបានអនុម័តលើសមាសភាពគណៈកម្មាធិការតែងតាំងរបស់ក្រុមប្រឹក្សាភិបាល ដើម្បីរៀបចំប្រកាសជ្រើសរើសបេក្ខភាព អភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន និងផ្ទេរសិទ្ធិជូនឯកឧត្តមអគ្គនាយក រ.ទ.ស.ភ. ដើម្បីត្រៀមរៀបចំចាត់ចែងដំណើរការមហាសន្និបាតលើកទី៧។

៦. អនុម័ត-ឯកភាពជាឯកច្ឆន្ទតាមសំណើសុំពិនិត្យ-អនុម័តលើដំណើរការរៀបចំបើកប្រាក់បៀវត្សរ៍ជូនមន្ត្រី-និយោជិតចំនួន០២ដង/ខែ និងកែសម្រួលប្រព័ន្ធបើកប្រាក់បៀវត្សរ៍បច្ចុប្បន្ន។

៧. អនុម័ត-ឯកភាពតាមសំណើសុំបង្កើតការិយាល័យទីផ្សារ និងសេវាកម្ម ក្នុងសាខាសេវាកម្មទឹកស្អាត និងអនាម័យ។

៨. បានឯកភាពលើកយករបាយការណ៍ស្តីពីផែនការដាក់បំពង់មេនាំទឹកពី ឆ្នាំ២០១៧ ដល់ឆ្នាំ២០២៦ ទៅពិភាក្សាក្នុងកិច្ចប្រជុំវិសាមញ្ញ នាដើមខែមករា ឆ្នាំ២០១៩។

១០. អនុម័ត-សម្រេចប្រគល់សិទ្ធិជូន ឯកឧត្តមបណ្ឌិត ស៊ឹម ស៊ីថា អគ្គនាយក រ.ទ.ស.ភ. ជាតំណាង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដើម្បីចរចារ និងចុះហត្ថលេខា ជាមួយរាជរដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើកិច្ចព្រមព្រៀងសម្រាប់គម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែងចំនួនបី។

## ការរំពឹងទុកសម្រាប់ត្រីមាសខាងមុខ

ដើម្បីឈានឆ្ពោះទៅសម្រេចទស្សនវិស័យរបស់ រ.ទ.ស.ភ. នឹងធ្វើការងារសំខាន់ៗ ដូចខាងក្រោម៖

- ការអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស
- ការអភិវឌ្ឍន៍មធ្យោបាយ និងសម្ភារប្រើប្រាស់
- សូចនករសេវាកម្ម និងសូចនករប្រសិទ្ធភាពការងារ។

បណ្តាសូចនករសំខាន់ៗ ដែលត្រូវតាមដាន និងត្រួតពិនិត្យមានដូចខាងក្រោម៖

- ផ្ទៃសេវាផ្គត់ផ្គង់ទឹកស្អាតនៅរាជធានីភ្នំពេញ: ១០០% នៅឆ្នាំ ២០២៥
- អត្រាដំណើរការសហគ្រាស: ទាបជាង ៤០%
- អត្រាទារប្រាក់ថ្លៃប្រើប្រាស់ទឹក: មិនទាបជាង ៩៩%
- អត្រាទឹកបាត់បង់: ក្នុងកម្រិត ៨%

រ.ទ.ស.ភ. មានយុទ្ធសាស្រ្តច្បាស់លាស់ក្នុងការពង្រីកបណ្តាញចែកចាយទឹក ដោយមានទំនាក់ទំនងជាមួយនឹងការពង្រីកសមត្ថភាពប្រព្រឹត្តកម្ម ហើយការពង្រីកការផ្គត់ផ្គង់ទឹកទៅតំបន់ជុំវិញរាជធានីភ្នំពេញ គឺធ្វើយ៉ាងណារក្សាអត្រា និងស្តង់ដារដូចគ្នា នៅក្នុងរាជធានីភ្នំពេញ និងតាំងចិត្តខ្ពស់ ចំពោះការទទួលខុសត្រូវដល់សង្គម និងបរិស្ថាន។ សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៩ យើងគ្រោងផលិតទឹកស្អាត ៥០.៨៣៧.០០០ម៣ ជាមួយនឹងការពង្រីកបណ្តាញចែកចាយទឹកបន្ថែម ៦៧.៧០០ម៉ែត្រ និងបង្កើនអតិថិជនថ្មីចំនួន ៥.៤០០បណ្តាញ ដោយគ្រោងចំណូលសរុបចំនួន៥៩.៨១២.៩៤៥.០០០រៀល និងចំណាយសរុបចំនួន ៤៩.៤៩៦.៥៨៧.០០០រៀល ដូចដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងក្រសួងអាណាព្យាបាលទាំងពីរ។

## សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងសេចក្តីដឹងគុណដ៏ជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល អាណាព្យាបាលទាំងពីរ គឺក្រសួងឧស្សាហកម្ម និង សិប្បកម្ម និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងភាគហ៊ុនិកទាំងអស់ ដែលបានផ្តល់ទំនុកចិត្ត និងការគាំទ្រចំពោះរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

យើងក៏មានមោទនភាព និងសូមថ្លែងអំណរគុណចំពោះមន្រ្តី និងនិយោជិតគ្រប់ថ្នាក់ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលបានខិតខំបំពេញការងារ ដោយស្មារតីទទួលខុសត្រូវខ្ពស់ ជំរុញឲ្យបានសម្រេចនូវលទ្ធផលដ៏ល្អប្រសើរនេះ។

ថ្ងៃសុក្រ ៣រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩

**ប្រធានក្រុមប្រឹក្សាភិបាល**

**ស៊ឹម ណារ៉ា**

# ៤: របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញ ដោយសវនករឯករាជ្យ

## សម្រាប់រយៈពេល១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨



លេខបញ្ជីពាណិជ្ជកម្ម

Co. ០៨៣៩ Et/២០១២

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
# (ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

# ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្ដោះអាសន្ន
# សម្រាប់រយៈពេល ១២ខែ គិតត្រឹមថ្ងៃទី ៣១ ធ្នូ ២០១៨

ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្ដោះអាសន្ន ដែលភ្ជាប់មកជាមួយ គឺជាការប្រែសំរួលជាភាសាខ្មែរ ពីរបាយការណ៍ជាភាសាអង់គ្លេស។ ក្នុងករណីមានភាពមិនស្របគ្នារវាងភាសាទាំងពីរ ឯកសារអង់គ្លេស ត្រូវបានយកជាគោល។

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**មាតិកា** **ទំព័រ**


| | |
|---|---|
| សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល | ១ |
| របាយការណ៍នៃការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន | ២ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេប | ៣ - ៤ |
| របាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗសង្ខេប | ៥ |
| របាយការណ៍បម្រែបម្រួលមូលធនសង្ខេប | ៦ |
| របាយការណ៍លំហូរសាច់ប្រាក់សង្ខេប | ៧ - ៨ |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ | ៩ - ២៦ |

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល**

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុសង្ខេបរបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហៅកាត់ថា ("រ.ទ.ស.ភ") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ព្រមទាំងរបាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗសង្ខេប របាយការណ៍បម្រែបម្រួលមូលធនសង្ខេប និង របាយការណ៍លំហូរសាច់ប្រាក់សង្ខេប សម្រាប់ត្រីមាស និង កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុបន្ថែមផ្សេងៗ (ត្រូវបានគេ ស្គាល់ផងដែរថាជា "ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន") បានរៀបចំឡើងត្រឹមត្រូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ ទៅតាមស្តង់ដារគណនេយ្យអន្តរជាតិកម្ពុជា លេខ ៣៤ ស្តីពី "*របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា*"។

ចុះហត្ថលេខាជំនួសក្រុមប្រឹក្សាភិបាល

**ស៊ឹម ស៊ីថា**
អគ្គនាយក

**រស់ គឹមលាង**
អគ្គនាយករងទទួលបន្ទុក
ហិរញ្ញកិច្ច និងផ្សារមូលបត្រ

**ស៊ឹម ណារ៉ា**
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃសុក្រ ៣រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩

BDO

Tel: +855 23 218 128
Fax:+855 23 993 225
www.bdo.com.kh

Suite 28 Hotel Cambodiana
313 Sisowath Quay
Phnom Penh
Kingdom of Cambodia



# របាយការណ៍នៃការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ជូនចំពោះភាគហ៊ុនិករបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា លេខ Co. ០៨៣៩ Et/២០១២)

## សេចក្តីផ្តើម

យើងខ្ញុំបានធ្វើការត្រួតពិនិត្យនូវរបាយការណ៍ហិរញ្ញវត្ថុសង្ខេបរបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហៅកាត់ថា "រ.ទ.ស.ភ" ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេប សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ព្រមទាំងរបាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗសង្ខេប របាយការណ៍បម្រែបម្រួលមូលធនសង្ខេប និងរបាយការណ៍លំហូរសាច់ប្រាក់សង្ខេបសម្រាប់រយៈពេល ១២ខែ និងសេចក្តីសង្ខេបកំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុបន្ថែមផ្សេងៗ (ត្រូវបានគេស្គាល់ផងដែរថាជា "ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន")។ អគ្គនាយករបស់ រ.ទ.ស.ភ ជាអ្នកទទួលការខុសត្រូវក្នុងការរៀបចំ និងបង្ហាញនូវព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន។ ទំនួលខុសត្រូវរបស់យើងខ្ញុំគឺ ធ្វើការសន្និដ្ឋានទៅលើព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នដោយផ្អែកលើការត្រួតពិនិត្យរបស់យើងខ្ញុំ។

## វិសាលភាពនៃការត្រួតពិនិត្យ

យើងខ្ញុំបានធ្វើការត្រួតពិនិត្យ ដោយអនុលោមតាមស្តង់ដារអន្តរជាតិកម្ពុជាលើការត្រួតពិនិត្យលេខ ២៤១០ ស្តីពី "ការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុក្នុងគ្រា ដែលធ្វើឡើងដោយសវនករឯករាជ្យរបស់ រ.ទ.ស.ភ"។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុរួមមាន ការចោទសួរបុគ្គលិកដែលពាក់ព័ន្ធផ្ទាល់នឹងព័ត៌មានហិរញ្ញវត្ថុ និងបញ្ហាគណនេយ្យ ព្រមទាំងការអនុវត្តនូវការវិភាគ និងនិតិវិធីក្នុងការត្រួតពិនិត្យផ្សេងៗ។ ការត្រួតពិនិត្យមានវិសាលភាពតិចជាងការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ហើយជាលទ្ធផល យើងខ្ញុំមិនអាចធ្វើការធានាថាបានដឹងនូវរាល់បញ្ហាសំខាន់ៗដែលអាចនឹងកំណត់បានប្រសិនបើធ្វើសវនកម្ម។ ដូច្នេះយើងខ្ញុំមិនបញ្ចេញមតិយោបល់សវនកម្មនោះទេ។

## សេចក្តីសន្និដ្ឋាន

យោងតាមការត្រួតពិនិត្យរបស់យើងខ្ញុំ យើងខ្ញុំកត់សម្គាល់ឃើញថាមិនមានបញ្ហាណាមួយដែលធ្វើអោយយើងខ្ញុំជឿជាក់ថាព័ត៌មានហិរញ្ញវត្ថុក្នុងគ្រាសង្ខេបរបស់ រ.ទ.ស.ភ ដែលបានភ្ជាប់មកជាមួយនេះមិនបានរៀបចំឡើងគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ មិនស្របទៅតាមស្តង់ដារគណនេយ្យអន្តរជាតិកម្ពុជាលេខ ៣៤ ស្តីពី "របាយការណ៍-ហិរញ្ញវត្ថុក្នុងគ្រា" នោះទេ។

BDO Cambodia

BDO (CAMBODIA) LIMITED

**ប៊ី ឌី អូ (ខេមបូឌា) លីមីធីត**

រាជធានីភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃសុក្រ ៣រោច ខែមាឃ ឆ្នាំច នព្វស័ក ព.ស. ២៥៦២

ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩

BDO (Cambodia) Limited, Certified Public Accountants, a Cambodian limited liability company, is a member of BDO International Limited, a UK company limited by guarantee, and forms part of the international BDO network of independent member firms.

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេប
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម ៣១ ធ្នូ ២០១៨ គិតជាពាន់រៀល | បានធ្វើសវនកម្ម ៣១ ធ្នូ ២០១៧ គិតជាពាន់រៀល |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៤ | ១.៧១៥.៤៧៥.៨២៣ | ១.១២៤.១៧២.១៨៣ |
| ទ្រព្យសកម្មអរូបី | | ១៤.៣២៦.០៩២ | ៥.២១១.៤០៦ |
| ឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | | - | ១១២.៨៩៦ |
| | | ១.៧២៩.៨០១.៩១៥ | ១.១២៩.៤៩៦.៤៨៥ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| សន្និធិ | | ៩៧.០១៤.១៧៨ | ៦៤.៥២៦.១២៤ |
| គណនីពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | | ១៨.៤៦៨.០១០ | ៤៤.៨០៤.១៧២ |
| កិច្ចសន្យាទ្រព្យសកម្ម | | ៤៦.០៤១.៧៦៩ | - |
| ឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | | ១១២.៣៦៥ | ១៤១.៨៤៩ |
| ឥណទានផ្តល់ឲ្យបុគ្គលិក | | ៥.៤៧៨.៣៥០ | ៥.០៣៤.៨៦៤ |
| វិនិយោគរយៈពេលខ្លី | ៥ | ៣៣.៦២២.៤១៧ | ៩៦.៧០៣.៧០៤ |
| គណនីពន្ធផ្សេងៗត្រូវទទួល | | ៥.៣១២.០៥២ | ៥.៣១២.០៥២ |
| សមតុល្យសាច់ប្រាក់ និងធនាគារ | | ១៣.៣៥៣.៧៥៨ | ១៥.៩៩២.៥២៧ |
| | | ២១៩.៤០២.៨៩៩ | ២៣២.៥១៥.២៩២ |
| **ទ្រព្យសកម្មសរុប** | | ១.៩៤៩.២០៤.៨១៤ | ១.៣៦២.០១១.៧៧៧ |
| **មូលធន និងបំណុល** | | | |
| **មូលធនភាគហ៊ុនិក** | | | |
| ដើមទុន | | ៥៤១.២២៧.២៨២ | ៥៤១.២២៧.២៨២ |
| ទុនបម្រុង | ៦ | ២៨៤.៥០៣.៦៣៦ | ២៦៤.៨២៩.៦៧៨ |
| ចំណេញរក្សាទុក | | ៧៧.៣៩១.២៨៥ | ៣៣.០៦៧.៨២៦ |
| **មូលធនរបស់ភាគហ៊ុនិកសរុប** | | ៩០៣.១២២.២០៣ | ៨៣៩.១២៤.៧៨៦ |
| **បំណុល** | | | |
| **បំណុលរយៈពេលវែង** | | | |
| ប្រាក់កម្ចី | ៧ | ២៨៥.៦៣៥.៩០១ | ២៥៨.២៨៦.៩០៣ |
| កាតព្វកិច្ចសោធននិវត្តន៍ | ៨ | - | ៤០.១៣៣.៧១៧ |
| ជំនួយពន្យារពីរដ្ឋាភិបាល និងជំនួយផ្សេងៗ | ៩ | ២៣.១៣១.០២៩ | ២៥.៤៩១.០០១ |
| បំណុលពន្ធពន្យារ | | ៤៧.១៥៥.៥៩៥ | ៣៥.២០៧.៣៥៩ |
| គណនីត្រូវបង់ផ្សេងៗ | ១០ | ៥៦.៨៤៨.៦២៣ | ៤៩.៦៩៩.៨៩៨ |
| | | ៤១២.៧៧១.១៤៨ | ៤០៨.៨១៨.៨៧៨ |

*របាយការណ៍ស្ថានភាពហិរញ្ញវត្ថុក្នុងគ្រាសង្ខេបគួរតែអានជាមួយនឹងព័ត៌មានហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដែលបានធ្វើសវនកម្មរួច ព្រមទាំងកំណត់សម្គាល់ដែលបានភ្ជាប់ក្នុងរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ននេះ។*

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេប(ត)
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម ៣១ ធ្នូ ២០១៨ គិតជាពាន់រៀល | បានធ្វើសវនកម្ម ៣១ ធ្នូ ២០១៧ គិតជាពាន់រៀល |
|---|---|---|---|
| **បំណុលរយៈពេលខ្លី** | | | |
| គណនីពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | ១០ | ៦៩.៨៩០.៤៤៣ | ៥១.១៤៥.១៣៤ |
| ប្រាក់កម្ចី | ៧ | ៤២.១១៨.៦២៩ | ៤៩.៣៥០.៦៨៤ |
| កិច្ចសន្យាបំណុល | | ៣៦.៦៤៥ | - |
| បំណុលភាគលាភ | ១១ | ៦.៨៨៤.៧៨៧ | - |
| ពន្ធលើប្រាក់ចំណេញត្រូវបង់ | | ១៤.៣៨០.៩៥៩ | ១៣.៥៧២.២៩៥ |
| | | ១៣៣.៣១១.៤៦៣ | ១១៤.០៦៨.១១៣ |
| **បំណុលសរុប** | | ៥៤៦.០៨២.៦១១ | ៥២២.៨៨៦.៩៩១ |
| **មូលធនរបស់ភាគហ៊ុនិក និង បំណុលសរុប** | | ១.៤៤៩.២០៤.៨១៤ | ១.៣៦២.០១១.៧៧៧ |

*របាយការណ៍ស្ថានភាពហិរញ្ញវត្ថុក្នុងគ្រាសង្ខេបគួរតែអានជាមួយនឹងព័ត៌មានហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ដែលបានធ្វើសវនកម្មរួច ព្រមទាំងកំណត់សម្គាល់ដែលបានភ្ជាប់ក្នុងរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ននេះ។*

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗសង្ខេប
## សម្រាប់រយៈពេល ១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | | មិនបានធ្វើសវនកម្ម | | | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី | | សម្រាប់រយៈពេល ១២ខែ គិតត្រឹមថ្ងៃទី | |
| | | ៣១ ធ្នូ ២០១៨(១) | ៣១ ធ្នូ ២០១៧(២) | ៣១ ធ្នូ ២០១៨(១) | ៣១ ធ្នូ ២០១៧(២) |
| | | គិតជាពាន់រៀល | គិតជាពាន់រៀល | គិតជាពាន់រៀល | គិតជាពាន់រៀល |
| ចំណូល៖ | | | | | |
| ការលក់ | | ៥២.៩២៨.៨០០ | ៤៧.០៦២.១១៩ | ២០៥.៨៤១.៤៩៨ | ១៩៣.៣៥៦.៤៤៥ |
| ចំណូលពីការសាងសង់ | | ៦៩០.៥៤២ | ១.២៥៧.១៣២ | ៨.០៩២.១០៣ | ១០.៧៤១.៥៣៦ |
| ចំណូលផ្សេងៗ | | ៣៧.៦២៧.០៦៨ | ១៥.៩៦៤.០៤៦ | ៥១.១៥៩.៦៩២ | ២៨.៧៩៥.១០៨ |
| | | ៩១.២៤៦.៤១០ | ៦៤.២៨៣.២៩៧ | ២៦៥.០៩៣.២៩៣ | ២៣២.៨៩៣.០៨៩ |
| ចំណាយ៖ | | | | | |
| ចំណាយរំលស់ទ្រព្យសកម្មរូបី និង ទ្រព្យសកម្មអរូបី | | (១១.៩៦៧.០៧១) | (៩.១៦៤.៥១២) | (៤៣.០៦៩.៥២៤) | (៣៦.៩៧៧.៩៣២) |
| ចំណាយថ្លៃភ្លើង | | (៩.១៥២.៨៨៧) | (៩.៣២៩.១៨៩) | (៣៨.៨២៦.៧៣២) | (៣៦.៦៩៤.១៨៧) |
| ចំណាយប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធផ្សេងៗ | | (១២.០០៣.៨៩៤) | (១០.៩៥១.៦០២) | (៤៨.៧២៥.៤៦០) | (៤០.៧៨០.៤៩២) |
| ចំណាយវត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត | | (២.១២៥.៤១៩) | (១.៨០២.០០៣) | (៧.៥០២.៦៦៧) | (៦.៧៥៥.៦២៣) |
| ចំណាយវត្ថុធាតុដើមសម្រាប់តភ្ជាប់បណ្តាញទៅតាមគេហដ្ឋាន | | (៩៧៥.៣៩៣) | (២.១៣៧.១១៤) | (៣.៥៥៦.៩០៥) | (៩.០៥៥.៦៨២) |
| ចំណាយជួសជុល និងថែទាំ | | (៣.១២១.២០៣) | (១.៥៧៤.៨១៨) | (៨.៣១៣.២៧៩) | (៧.៨៩២.៩៧១) |
| ចំណាយសេវាសាងសង់ | | ៣៦៦.៧៦៤ | (៧០.៨២៣) | (៥.៦៧២.៣៣៩) | (៧.០៤៨.០២៤) |
| សំវិធានធនលើឥណទានផ្តល់ឲ្យបុគ្គលិក | | ១.២៥២.១៩៤ | (៣៩.១៣១) | ៤៤៣.៤៨៥ | (៦១៣.០៥៣) |
| ខាតពីការប្តូររូបិយប័ណ្ណ - សុទ្ធ | | (៥០២.២៩៥) | (៤១៩.៩៦៤) | (៩៤១.៨២២) | (២៦៣.៤៧១) |
| ចំណាយប្រតិបត្តិការផ្សេងៗ | | (២.១២៦.៦១២) | (២.១០២.៤១២) | (៨.៧៨៥.៨២៧) | (៧.៣២៥.០៥៦) |
| ចំណេញប្រតិបត្តិការ | | ៥០.៨៩០.៥៩៤ | ២៦.៦៩១.៧២៩ | ១០០.១៤២.២២៣ | ៧៩.៤៨៦.៥៩៨ |
| ចំណូលការប្រាក់ | ១២ | ៧.៥២០.២០៩ | ១.០៣៧.៧៧៤ | ១៦.៨១៤.២៥៤ | ៦.១៤៤.៩២៦ |
| ចំណាយការប្រាក់ | ១២ | (១.៩៦០.៤៥៩) | (៣.៩៩៤.០៦១) | (១៦.១៧៦.៨២៧) | (៣២.៨០៤.៧៣៩) |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | | ៥៦.៤៥០.៣៤៤ | ២៣.៧៣៥.៤៤២ | ១០០.៧៧៩.៦៥០ | ៥២.៨២៦.៧៨៥ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១៣ | (១០.៨៥៧.១១១) | (១៣.១៩៤.០២១) | (២០.៤៩៤.៨២៨) | (១៦.៨៩២.៥៨២) |
| ចំណេញក្នុងការិយបរិច្ឆេទ | | ៤៥.៥៩៣.២៣៣ | ១០.៥៤១.៤២១ | ៨០.២៨៤.៨២២ | ៣៥.៩៣៤.២០៣ |
| ចំណូលលម្អិតផ្សេងៗ | | | | | |
| ខ្ទង់គណនីដែលមិនបានបែងចែកចំណេញ ឬខាត៖ | | | | | |
| ខាតពីការវាយតម្លៃហានិភ័យកាតព្វកិច្ចសោធននិវត្តន៍ | | (៣.០១២.១៥១) | (២៧.៦២៥) | (២.៨៩៣.៥៣៧) | (២.៨៦៦.៣៧៧) |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | ៤២.៥៨១.០៨២ | ១០.៥១៣.៧៩៦ | ៧៧.៣៩១.២៨៥ | ៣៣.០៦៧.៨២៦ |

ចំណេញក្នុង១ភាគហ៊ុន (ជាប្រាក់រៀល) របស់ភាគហ៊ុន និង រ.ទ.ស.ភ ក្នុងការិយបរិច្ឆេទនេះមានដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| ចំណេញក្នុងមួយភាគហ៊ុនមូលដ្ឋាន | ១៤ | ៤៨៩,៥៩ | ១២០,៨៩ | ៨៨៩,៨៣ | ៣៨០,២១ |
| ចំណេញក្នុងមួយភាគហ៊ុនថយចុះ | ១៤ | ៤៨៩,៥៩ | ១២០,៨៩ | ៨៨៩,៨៣ | ៣៨០,២១ |

***កំណត់សម្គាល់៖***

*(១) របាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗសង្ខេប គួរតែអានជាមួយនឹងព័ត៌មានហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៧ ដែលបានធ្វើសវនកម្មរួច ព្រមទាំងកំណត់សម្គាល់ដែលបានភ្ជាប់ក្នុងរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ននេះ។*

*(២) តួលេខដែលយកមកប្រៀបធៀបសម្រាប់ការិយបរិច្ឆេទ បានពិនិត្យឡើងវិញ ប៉ុន្តែមិនបានធ្វើសវនកម្ម។*

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍បម្រែបម្រួលមូលធនសង្ខេប
## សម្រាប់រយៈពេល ១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | កំណត់សម្គាល់ | មូលធនភាគហ៊ុន គិតជាពាន់រៀល | ទុនបម្រុង គិតជាពាន់រៀល | ចំណេញរក្សាទុក គិតជាពាន់រៀល | សរុប គិតជាពាន់រៀល |
|---|---|---|---|---|---|
| **មិនបានធ្វើសវនកម្ម** | | | | | |
| **សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៨** | | **៥៤១.២២៧.២៨២** | **២៦៤.៨២៩.៦៧៨** | **៣៣.០៦៧.៨២៦** | **៨៣៩.១២៤.៧៨៦** |
| ចំណេញក្នុងការិយបរិច្ឆេទ | | - | - | ៨០.២៨៤.៨២២ | ៨០.២៨៤.៨២២ |
| ខាតដែលបណ្តាលមកពីការវាយតម្លៃ ហានិភ័យសោធននិវត្តន៍ | | - | - | (២.៩៩៣.៥៣៧) | (២.៩៩៣.៥៣៧) |
| លទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ | | - | - | ៧៧.៣៩១.២៨៥ | ៧៧.៣៩១.២៨៥ |
| *ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន* | | | | | |
| ការផ្ទេរទៅគណនីទុនបម្រុង | ៦ | - | ១៩.៦៧៣.៩៥៨ | (១៩.៦៧៣.៩៥៨) | - |
| ភាគលាភបានបង់ | ១១ | - | - | (១៣.៣៩៣.៨៦៨) | (១៣.៣៩៣.៨៦៨) |
| សរុបប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន | | - | ១៩.៦៧៣.៩៥៨ | (៣៣.០៦៧.៨២៦) | (១៣.៣៩៣.៨៦៨) |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨[១]** | | **៥៤១.២២៧.២៨២** | **២៨៤.៥០៣.៦៣៦** | **៧៧.៣៩១.២៨៥** | **៩០៣.១២២.២០៣** |
| **សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៧** | | **៥៤១.២២៧.២៨២** | **២២៩.៤៧១.៤១០** | **៤៩.២៧៣.១០៤** | **៨១៩.៩៧១.៧៩៦** |
| ចំណេញក្នុងការិយបរិច្ឆេទ | | - | - | ៣៥.៩៣៤.២០៣ | ៣៥.៩៣៤.២០៣ |
| ចំណេញដែលបណ្តាលមកពីការវាយតម្លៃ ហានិភ័យសោធននិវត្តន៍ | | - | - | (២.៨៦៦.៣៧៧) | (២.៨៦៦.៣៧៧) |
| លទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ | | - | - | ៣៣.០៦៧.៨២៦ | ៣៣.០៦៧.៨២៦ |
| *ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន* | | | | | |
| ការផ្ទេរទៅគណនីទុនបម្រុង | ៦ | - | ៣៥.៣៥៨.២៦៨ | (៣៥.៣៥៨.២៦៨) | - |
| ភាគលាភបានបង់ | ១១ | - | - | (១៣.៩១៤.៨៣៦) | (១៣.៩១៤.៨៣៦) |
| សរុបប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន | | - | ៣៥.៣៥៨.២៦៨ | (៤៩.២៧៣.១០៤) | (១៣.៩១៤.៨៣៦) |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧[២]** | | **៥៤១.២២៧.២៨២** | **២៦៤.៨២៩.៦៧៨** | **៣៣.០៦៧.៨២៦** | **៨៣៩.១២៤.៧៨៦** |

***កំណត់សម្គាល់៖***

*(១) របាយការណ៍បម្រែបម្រួលសង្ខេប គួរតែអានជាមួយនឹងព័ត៌មានហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៧ ដែលបានធ្វើសវនកម្មរួច ព្រមទាំងកំណត់សម្គាល់ដែលបានភ្ជាប់ក្នុងរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ននេះ។*

*(២) តួលេខដែលយកមកប្រៀបធៀបសម្រាប់ការិយបរិច្ឆេទ បានពិនិត្យឡើងវិញ ប៉ុន្តែមិនបានធ្វើសវនកម្ម។*

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់សង្ខេប
## សម្រាប់រយៈពេល ១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | កំណត់សម្គាល់ | សម្រាប់រយៈពេល ១២ខែ គិតត្រឹមថ្ងៃទី<br>មិនបានធ្វើសវនកម្ម<br>៣១ ធ្នូ ២០១៨(១)<br>គិតជាពាន់រៀល | បានធ្វើសវនកម្ម<br>៣១ ធ្នូ ២០១៧(២)<br>គិតជាពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | |
| ចំណេញមុនបង់ពន្ធ | | ១០០.៧៧៩.៦៥០ | ៥២.៨២៦.៧៨៥ |
| និយ័តកម្ម៖ | | | |
| រំលស់ទ្រព្យសកម្មអរូបី | | ១.៧៦២.២១០ | ៩៥៣.៤០២ |
| រំលស់ជំនួយពន្ធារពីរដ្ឋាភិបាល និងជំនួយផ្សេងៗ | | (២.៣៥៩.៩៧២) | (២.៣៥៩.៩៧៣) |
| រំលស់ទ្រព្យសកម្មរូបី | | ៤១.៣០៧.៣១៤ | ៣៦.០២៤.៥៣០ |
| ចំណូលការប្រាក់ | | (១៦.៨១៤.២៥៤) | (៦.១៤៤.៩២៦) |
| ចំណាយការប្រាក់ | | ១៦.១៧៦.៨២៧ | ៣២.៨០៤.៧៣៩ |
| សំវិធានធនលើឥណទានផ្តល់ឲ្យបុគ្គលិក | | (៤៤៣.៤៨៥) | ៥៧៣.៩២៣ |
| ចំណេញពីការទូទាត់នៃកាតព្វកិច្ចសោធននិវត្តន៍ | ៨ | (៣២.៩២៨.១៤៣) | - |
| ការជម្រះពីបញ្ជីនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | ៣.៨២២.១០៧ | ៤៥០.៨៧៥ |
| ចំណាយកាតព្វកិច្ចសោធននិវត្តន៍ | ៨ | ៥.៤១៥.៩៣៧ | ៤.៤៧១.៨២២ |
| ចំណូលប្រតិបត្តិការមុនបម្រែបម្រួលដើមទុនបង្វិល | | ១១៦.៧១៨.១៩១ | ១១៩.៦០១.១៧៧ |
| បម្រែបម្រួលដើមទុនបង្វិល៖ | | | |
| សន្និធិ | | (៣២.៤៨៨.០៥៤) | (១៦.១៣១.៧២១) |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | | ២៤.៩៦៤.៤៩៩ | (៩.៨២០.១៦៨) |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | | ២៣.៩០៩.៨៥៦ | (៣.៧៣១.៩១០) |
| កិច្ចសន្យាទ្រព្យសកម្ម | | (៤៦.០៤១.៧៦៩) | - |
| កិច្ចសន្យាបំណុល | | ៣៦.៦៤៥ | - |
| ប្រាក់កក់របស់អតិថិជន | | ៤.៨៤៨.០៦៥ | ៤.០៧១.៧០៣ |
| សាច់ប្រាក់បានមកពីប្រតិបត្តិការ | | ៩១.៩៤៧.៤៣៣ | ៩៣.៩៨៩.០៨១ |
| ចំណាយពន្ធបានបង់ | | (៧.៧៣៧.៩២៨) | (៩.៤១៧.៧១៨) |
| កាតព្វកិច្ចសោធននិវត្តន៍បានបង់ | | (១.៣០២.៦៦៤) | (១.១៨៧.៩៥៩) |
| សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពប្រតិបត្តិការ | | ៨២.៩០៦.៨៤១ | ៨៣.៣៨៣.៤០៤ |
| **លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពវិនិយោគ** | | | |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៤ | (១៦១.៦៣៩.២៨៣) | (១១៥.៤៤៧.៤២០) |
| មូលធនការប្រាក់លើទ្រព្យសម្បត្តិដែលមានលក្ខណៈគ្រប់គ្រាន់ | | (២.៧២០.១៥៩) | (៧៥៥.០១៩) |
| ការទិញទ្រព្យសកម្មអរូបី | | (២៦.៧៨៦) | (២៧.៥៨១) |
| ទឹកប្រាក់សំណងពីឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | | ១៤២.៣៨០ | ១២៣.១១២ |
| ការវិនិយោគរយៈពេលខ្លី | | ៦៣.០៨១.២៨៧ | ៥១.៥៦៧.៦៨០ |
| ការប្រាក់បានទទួល | | ២.៥៥៣.៦១៣ | ៤.៤១៥.៣៤៧ |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ | | (៩៨.៦០៨.៩៤៨) | (៦០.១២៣.៨៨១) |

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**របាយការណ៍លំហូរសាច់ប្រាក់សង្ខេប** (ត)
**សម្រាប់រយៈពេល ១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

| | | សម្រាប់រយៈពេល ១២ខែ គិតត្រឹមថ្ងៃទី | |
|---|---|---|---|
| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម ៣១ ធ្នូ ២០១៨[១] | បានធ្វើសវនកម្ម ៣១ ធ្នូ ២០១៧[២] |
| | | គិតជាពាន់រៀល | គិតជាពាន់រៀល |
| **លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពហិរញ្ញប្បទាន** | | | |
| ភាគលាភដែលបានបង់ | | (៦.៥០៩.០៨១) | (១៣.៩១៤.៨៣៦) |
| សាច់ប្រាក់បានមកពីប្រាក់កម្ចី | | ៧៣.៣៣៩.២១១ | ២៤.៦៦៥.៥៦៦ |
| ការប្រាក់បានបង់ | | (៧.៩៩៤.៩៨១) | (៨.៧៤១.៤៩៥) |
| ការបង់សងប្រាក់កម្ចី | | (៤៥.៧៧១.៨១១) | (២៥.៦៦៣.០៨០) |
| សាច់ប្រាក់សុទ្ធបានមកពី/(ប្រើក្នុង)សកម្មភាពហិរញ្ញប្បទាន | | ១៣.០៦៣.៣៣៨ | (២៣.៦៥៣.៨៤៥) |
| **តំហយសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | (២.៦៣៨.៧៦៩) | (៣៩៤.៣២២) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមការិយបរិច្ឆេទ** | | ១៥.៩៩២.៥២៧ | ១៦.៣៨៦.៨៤៩ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងការិយបរិច្ឆេទ** | | ១៣.៣៥៣.៧៥៨ | ១៥.៩៩២.៥២៧ |

***កំណត់សម្គាល់៖***
*(១) របាយការណ៍បលំហូរសាច់ប្រាក់សង្ខេប គួរតែអានជាមួយនឹងព័ត៌មានហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៧ ដែលបានធ្វើសវនកម្មរួច ព្រមទាំងកំណត់សម្គាល់ដែលបានភ្ជាប់ក្នុងរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ននេះ។*
*(២) តួលេខដែលយកមកប្រៀបធៀបសម្រាប់ការិយបរិច្ឆេទ បានពិនិត្យឡើងវិញ ប៉ុន្តែមិនបានធ្វើសវនកម្ម។*

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុសង្ខេប
## ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

### ១. ព័ត៌មានអំពីក្រុមហ៊ុន

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហៅកាត់ថា ("រ.ទ.ស.ភ") ស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយមានការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ។ រ.ទ.ស.ភ ត្រូវបានទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម ថាជាសហគ្រាសសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច និងមានលេខចុះបញ្ជី Co.០៨៣៩ Et/២០១២ ចុះថ្ងៃទី ២៧ ខែមិនា ឆ្នាំ២០១២។

ការិយាល័យចុះបញ្ជីរបស់ រ.ទ.ស.ភ មានទីតាំងស្ថិតនៅអគារលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ព័ត៌មានហិរញ្ញវត្ថុក្នុងគ្រាសង្ខេបត្រូវបាន បង្ហាញជាប្រាក់រៀលដែលជារូបិយវត្ថុ រ.ទ.ស.ភ កំពុងប្រើប្រាស់ផងដែរ។

ព័ត៌មានហិរញ្ញវត្ថុក្នុងគ្រាសង្ខេប ត្រូវបានក្រុមប្រឹក្សាភិបាលអនុម័តឲ្យចេញផ្សាយនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០១៩។

### ២. សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ រ.ទ.ស.ភ គឺការផលិត និងការចែកចាយទឹកស្អាតសម្រាប់ការប្រើប្រាស់ទូទៅរបស់សាធារណជននៅរាជធានីភ្នំពេញ។ កម្មវត្ថុអាជីវកម្មរបស់ រ.ទ.ស.ភ គឺៈ

- វិនិយោគ កសាង ពង្រីក ដំណើរការជួសជុល និងថែរក្សាមធ្យោបាយសម្រាប់ផលិត និងប្រព័ន្ធចែកចាយទឹកស្អាត និងអនាម័យ
- ប្រើប្រាស់នូវគ្រប់វិធានការដើម្បីបង្កើនផលិតកម្ម-សេវាកម្ម និងធានាគុណភាពទឹកស្អាតឆ្លើយតបទៅនឹងតម្រូវការសម្រាប់ជីវភាពរស់នៅ អាជីវកម្ម-សេវាកម្ម និងឧស្សាហកម្ម
- ធ្វើអាជីវកម្ម-សេវាកម្ម និងការងារផ្សេងៗទៀតដែលទាក់ទងនឹងវិស័យទឹកស្អាត និងអនាម័យតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងអនុលោមតាមច្បាប់
- ធ្វើសហប្រតិបត្តិការលើផ្នែកបច្ចេកទេស ពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍ក្នុងស្រុក និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍន៍ រ.ទ.ស.ភ ទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ធានាឲ្យបាននូវចិរភាព ដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុ ដោយផ្សារភ្ជាប់ជាមួយផលប្រយោជន៍សង្គម។

### ៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្នមិនត្រូវបានធ្វើសវនកម្ម ហើយត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា លេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ន*។ របាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ននេះ គួរតែត្រូវបានអានផ្គួបផ្សំជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ និងកំណត់សម្គាល់មួយចំនួនដែលអមជាមួយ។

កំណត់សម្គាល់មួយចំនួន ត្រូវបានជ្រើសរើសដាក់ភ្ជាប់មកជាមួយដើម្បីពន្យល់ពីព្រឹត្តិការណ៍ និងប្រតិបត្តិការសំខាន់ៗ សម្រាប់ការស្វែងយល់ពីបម្រែបម្រួលនៃស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលអាជីវកម្មរបស់ រ.ទ.ស.ភ ចាប់គិតពីត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។

## ៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

គោលការណ៍គណនេយ្យ និងវិធីសាស្ត្រនៃការគណនាដែលបានអនុវត្ត គឺសមស្របទៅនឹងគោលការណ៍ និងវិធីសាស្ត្រដែលបានអនុវត្តនៅក្នុងការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ លើកលែងតែការអនុវត្តនៃស្តង់ដាគណនេយ្យ វិសោធនកម្ម និងបំណកស្រាយផ្សេងៗខាងក្រោម៖

| | ថ្ងៃចូលជាធរមាន |
|---|---|
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១ *ការពង្រឹងប្រចាំឆ្នាំ (ខួប២០១៤ ដល់ ២០១៦)* | ១ មករា ២០១៨ |
| ស.រ.ហ.អ.ក ១៥ *ចំណូលពីកិច្ចសន្យាជាមួយអតិថិជន* | ១ មករា ២០១៨ |
| ការបញ្ជាក់ពី ស.រ.ហ.អ.ក ១៥ | ១ មករា ២០១៨ |
| ស.រ.ហ.អ.ក ៩ *ឧបករណ៍ហិរញ្ញវត្ថុ (ចេញផ្សាយដោយ ក.ប.ស.គ.អ នៅខែកក្កដា ឆ្នាំ២០១៤)* | ១ មករា ២០១៨ |
| ស.រ.ហ.អ.ក ២ *ការបែងចែក និងការវាស់វែងតំលៃ នៃប្រតិបត្តិការទូទាត់ផ្អែកលើប័ណ្ណភាគហ៊ុន* | ១ មករា ២០១៨ |
| វិសោធនកម្មលើ ស.គ.អ.ក ២៨ *ការពង្រឹងប្រចាំឆ្នាំ (ខួប២០១៤ ដល់ ២០១៦)* | ១ មករា ២០១៨ |
| ការបកស្រាយ ២២ *ប្រតិបត្តិការរូបិយប័ណ្ណបរទេស និងបុរេប្រទាននៃតម្លៃតបស្នង* | ១ មករា ២០១៨ |
| វិសោធនកម្មលើ ស.គ.អ.ក ៤០ *ការផ្ទេរទ្រព្យសម្បត្តិវិនិយោគ* | ១ មករា ២០១៨ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ៤ *ដោយអនុវត្ត ស.រ.ហ.អ.ក ៩ ឧបករណ៍ហិរញ្ញវត្ថុ ជាមួយ* ស.រ.ហ.អ.ក ៤ *កិច្ចសន្យាធានារ៉ាប់រង* | យោងតាម ស.រ.ហ.អ.ក ៤ កថាខណ្ឌ៤៦ និង៤៨ |

ការអនុវត្តនូវវិសោធនកម្ម ស្តង់ដារគណនេយ្យ និង ការបកស្រាយមិនមានឥទ្ធិពលលើស្ថានភាពហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ លើកលែងតែការដាក់ឲ្យប្រើប្រាស់នូវ ស.រ.ហ.អ.ក ១៥ និង ស.រ.ហ.អ.ក ៩ ដែលនិងត្រូវបានបរិយាយដូចខាងក្រោម។

(ក) <u>*ស.រ.ហ.អ.ក ៩ ឧបករណ៍ហិរញ្ញវត្ថុ*</u>

ស.រ.ហ.អ.ក ៩ ត្រូវបានយកមកប្រើប្រាស់ជំនួស ស.រ.ហ.អ.ក ៣៩ *ឧបករណ៍ហិរញ្ញវត្ថុ៖ ការទទួលស្គាល់ និង ការវាស់វែង* សម្រាប់រយៈពេលប្រចាំឆ្នាំដែលចាប់ផ្តើមនៅ ឬ បន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ ២០១៨ រួមបញ្ចូលទិដ្ឋភាពទាំងបីនៃគណនេយ្យសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ៖ ការចាត់ថ្នាក់ និងការវាស់វែង. សំវិធានធននិងគណនេយ្យការពារហានិភ័យ(Hedge accounting)។

រ.ទ.ស.ភ បានអនុវត្ត ស.រ.ហ.អ.ក ៩ ដោយមានការដាក់ពាក្យស្នើសុំដំបូងនៅថ្ងៃទី១ ខែមករា ឆ្នាំ ២០១៨។ រ.ទ.ស.ភ មិនបានកំណត់ឡើងវិញនូវព័ត៌មានប្រៀបធៀប ដែលនៅតែបន្តដើម្បីរាយការណ៍នៅក្រោម ស.គ.អ.ក ៣៩។ ភាពខុសគ្នាដែលកើតមានពីការអនុវត្ត ស.រ.ហ.អ.ក ៩ ត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងប្រាក់ចំណេញរក្សាទុក និងសមាសភាគផ្សេងទៀតនៃមូលធន។

(១) ចំណាត់ថ្នាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

រ.ទ.ស.ភ បានធ្វើចំណាត់ថ្នាក់លើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ នៅក្នុងប្រភេទនៃការវាយតម្លៃអាស្រ័យលើគំរូអាជីវកម្មនៃ រ.ទ.ស.ភ សម្រាប់ការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលក្ខខណ្ឌនៃលំហូរសាច់ប្រាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុដូចខាងក្រោម៖

- ត្រូវបានវាស់វែងតាមតម្លៃរំលស់ និង
- ត្រូវបានវាស់វែងជាបន្តបន្ទាប់ក្នុងតម្លៃទីផ្សារតាមរយៈប្រាក់ចំណូលផ្សេងៗ ឬតាមរយៈប្រាក់ចំណេញ ឬខាត។

## ៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

(ក) *ស.រ.ហ.អ.ក ៩ ឧបករណ៍ហិរញ្ញវត្ថុ (ត)*

(១) ចំណាត់ថ្នាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

ខាងក្រោមនេះជាការសង្ខេបពីការផ្លាស់ប្តូរសំខាន់ៗ៖

- ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់("AFS"). ការរក្សាទុកដល់កាលកំណត់("HTM") និងប្រាក់កម្ចី និងគណនីត្រូវទទួល ("L&R") ជាប្រភេទទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានលុបចោល។
- ប្រភេទទ្រព្យសកម្មហិរញ្ញវត្ថុថ្មីដែលបានវាស់វែងនៅថ្លៃដើមរំលស់("AC") ត្រូវបានណែនាំ។ នេះសំដៅទៅលើទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានលក្ខណៈលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលជាការទូទាត់តែប្រាក់ដើម និងការប្រាក់ និងបានធ្វើឡើងនៅក្នុងគំរូអាជីវកម្មដែលមានគោលដៅសម្រេចបានដោយការប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា។
- ប្រភេទទ្រព្យសកម្មហិរញ្ញវត្ថុថ្មីមួយ ត្រូវបានវាស់វែងតាមតម្លៃទីផ្សារតាមរយៈប្រាក់ចំណូលផ្សេងទៀត("FVTOCI") ត្រូវបានចាប់ផ្តើម។ នេះត្រូវបានអនុវត្ត ឧបករណ៍បំណុលជាមួយលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលជាការទូទាត់ប្រាក់ដើម និងការប្រាក់ និងបានធ្វើឡើងនៅក្នុងគំរូអាជីវកម្មដែលគោលដៅត្រូវបានសម្រេច ដោយការប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ។
- ប្រភេទទ្រព្យសកម្មហិរញ្ញវត្ថុថ្មី សម្រាប់ការធ្វើវិនិយោគទុនដោយគ្មានការជួញដូរដែលបានវាស់វែងនៅ FVTOCI ត្រូវបានណែនាំ។

ស.រ.ហ.អ.ក ៩ ភាគច្រើនរក្សាទុក សម្រាប់តម្រូវការដែលមានស្រាប់នៅក្នុង ស.គ.អ.ក ៣៩ សម្រាប់ការចាត់ថ្នាក់បំណុលហិរញ្ញវត្ថុ។

ទោះបីជាយ៉ាងណា នៅក្រោម ស.គ.អ.ក ៣៩ រាល់ការផ្លាស់ប្តូរតម្លៃទីផ្សារនៃបំណុល ដែលបានកំណត់ជា FVTPL ត្រូវបានទទួលស្គាល់ក្នុងចំណេញឬ ការខាត ចំណែកឯនៅក្រោម ស.រ.ហ.អ.ក ៩ ការផ្លាស់ប្តូរតម្លៃទីផ្សារ ត្រូវបានបង្ហាញជាទូទៅដូចខាងក្រោម៖

- ចំនួនទឹកប្រាក់នៃការផ្លាស់ប្តូរនៃតម្លៃទីផ្សារ ដែលបណ្តាលមកពីការផ្លាស់ប្តូរហានិភ័យឥណទាននៃការទទួលខុសត្រូវនេះត្រូវបានបង្ហាញនៅក្នុងចំណូលផ្សេងទៀត និង
- ចំនួនទឹកប្រាក់ដែលនៅសល់នៃការផ្លាស់ប្តូរ នៅក្នុងតម្លៃទីផ្សារ ត្រូវបានបង្ហាញនៅក្នុងចំណេញ ឬ ខាត។

(២) ឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ

ការអនុម័ត ស.រ.ហ.អ.ក ៩ បានផ្លាស់ប្តូរគណនេយ្យមូលដ្ឋានសម្រាប់ការ ឱនភាពនៃការខាតបង់លើទ្រព្យសកម្មហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ដោយជំនួសវិធីសាស្ត្របាត់បង់ដែលបានកើតឡើងរបស់ ស.គ.អ.ក ៣៩ ជាមួយនឹងវិធីបាត់បង់ឥណទានដែលរំពឹងទុក។ ស.រ.ហ.អ.ក ៩ តម្រូវឱ្យ រ.ទ.ស.ភ កត់ត្រាប្រាក់សំវិធានធនសម្រាប់ការខាតបង់ឥណទាន ដែលគេរំពឹងទុកសម្រាប់ទ្រព្យសម្បត្តិហិរញ្ញវត្ថុបំណុលទាំងអស់ដែល មិនបានកាន់កាប់តាមតម្លៃទីផ្សារតាមរយៈប្រាក់ចំណេញ ឬ ខាត។

ការខាតបង់ឥណទានរំពឹងទុក គឺផ្អែកលើភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យាតាមរយៈកិច្ចសន្យា និងលំហូរសាច់ប្រាក់ទាំងអស់ដែល រ.ទ.ស.ភ រំពឹងទុកថាបទទួលបាន។ ការប៉ាន់ស្មាននៃកង្វះខាតសាច់ប្រាក់ដែលរំពឹងទុក ត្រូវឆ្លុះបញ្ចាំងពីលំហូរសាច់ប្រាក់ដែលរំពឹងទុកពីការបញ្ចាំនិងឥណទានផ្សេងទៀតដែលជាលក្ខខណ្ឌនៃកិច្ចសន្យា។ កង្វះខាតនេះនឹងត្រូវធ្វើអប្បហារត្រឹមតម្លៃសមស្របមួយទៅនឹងអត្រាការប្រាក់ជាក់ស្តែងនៃទ្រព្យសកម្មនោះ។

## ៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

(ក) *ស.រ.ហ.អ.ក ៩ ឧបករណ៍ហិរញ្ញវត្ថុ (ត)*

(២) ឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

ឱនភាពសម្រាប់គណនីពាណិជ្ជត្រូវទទួល និងកិច្ចសន្យាទ្រព្យសកម្ម ដែលមិនបានរួមបញ្ចូលជាធាតុនៃហិរញ្ញវត្ថុសំខាន់ គឺត្រូវបានទទួលស្គាល់វិធីសាស្ត្រសាមញ្ញ ជាមួយ ស.រ.ហ.អ.ក ៩ ដោយប្រើការរំពឹងទុកលើអាយុកាលការខាតបង់ឥណទាន។

នៅក្នុងអំឡុងពេលនៃដំណើរការនេះ លទ្ធភាពនៃការមិនទូទាត់ ដោយគណនីពាណិជ្ជកម្មត្រូវទទួល បានកែតម្រូវដោយព័ត៌មាន ហើយគុណនឹងចំនួនទឹកប្រាក់នៃការខាតបង់ដែលរំពឹងទុកដែលកើតឡើងពីលំនាំដើមដើម្បីកំណត់ការបាត់បង់ឥណទានដែលរំពឹងលើអាយុកាលសម្រាប់គណនីពាណិជ្ជកម្មត្រូវទទួល។ សម្រាប់គណនីពាណិជ្ជកម្មត្រូវទទួល ដែលត្រូវបានរាយការណ៍នូវចំនួនសុទ្ធ ឱនភាពទាំងនេះត្រូវបានកត់ត្រា ក្នុងគណនីដាច់ដោយឡែកជាមួយនឹងការខាតបង់ដែលត្រូវបានទទួលស្គាល់នៅក្នុងចំណាយរដ្ឋបាលនៅក្នុងរបាយការណ៍ប្រាក់ចំណេញឬខាត និងចំណូលផ្សេងៗទៀត។ នៅលើការបញ្ជាក់ថាគណនីពាណិជ្ជត្រូវទទួល នឹងមិនអាចប្រមូលបានតាមតម្លៃសុទ្ធនៃទ្រព្យសកម្មសរុបដែលត្រូវបានលុបចោល ជាមួយឱនភាពដែលពាក់ព័ន្ធ។

ឱនភាពសម្រាប់គណនីត្រូវទទួលពីភាគីពាក់ព័ន្ធត្រូវបានទទួលស្គាល់ ដោយផ្អែកលើវិធីសាស្ត្រទូទៅនៅក្នុង ស.រ.ហ.អ.ក ៩ ដោយប្រើវិធីសាស្ត្រដែលបាត់បង់ឥណទានរំពឹងទុកទៅមុខ។ វិធីសាស្ត្រដែលត្រូវបានប្រើដើម្បីកំណត់ចំនួនទឹកប្រាក់នៃឱនភាព ត្រូវបានផ្អែកលើថាតើមានការកើនឡើងគួរឱ្យកត់សម្គាល់នៃហានិភ័យឥណទាន ចាប់តាំងពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ។ ចំពោះគណនីត្រូវទទួលទាំងឡាយដែលហានិភ័យឥណទានមិនបានកើនឡើងយ៉ាងខ្លាំង ចាប់តាំងពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ការខាតបង់ឥណទានរំពឹងទុកក្នុងរយៈពេលដប់ពីរខែ រួមជាមួយនឹងចំណូលការប្រាក់សុទ្ធត្រូវបានទទួលស្គាល់។ ហើយចំពោះគណនី ត្រូវទទួលទាំងឡាយណាដែលហានិភ័យឥណទានមានការកើនឡើងយ៉ាងខ្លាំង ការរំពឹងទុកនៃឥណទានបាត់បង់តាមអាយុកាល រួមជាមួយចំណូលការប្រាក់ដុលត្រូវបានទទួលស្គាល់។ ចំពោះគណនីត្រូវទទួលដែលគិតថានឹងមានឱនភាពការរំពឹងទុកឥណទានបាត់បង់តាមអាយុកាល រួមជាមួយចំណូលការប្រាក់តាមមូលដ្ឋានសុទ្ធត្រូវបានទទួលស្គាល់។

(៣) ចំណាត់ថ្នាក់ និងការវាស់វែង

តារាងខាងក្រោមសង្ខេបការធ្វើចំណាត់ថ្នាក់និងការវាស់វែងឡើងវិញនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៨៖

| | **ចំណាត់ថ្នាក់** | | **តំលៃពិតគណនេយ្យ** | |
|---|---|---|---|---|
| | **មាននៅក្នុង ស.គ.អ.ក ៣៩ គិតជាពាន់រៀល** | **ថ្មីនៅក្នុង ស.រ.ហ.អ.ក ៩ គិតជាពាន់រៀល** | **មាននៅក្នុង ស.គ.អ.ក ៣៩ គិតជាពាន់រៀល** | **ថ្មីនៅក្នុង ស.រ.ហ.អ.ក ៩ គិតជាពាន់រៀល** |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| វិនិយោគរយៈពេលខ្លី | L&R | AC | ៩៦.៧០៣.៧០៤ | ៩៦.៧០៣.៧០៤ |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | L&R | AC | ៤៤.៨០៤.១៧២ | ៤៤.៨០៤.១៧២ |
| សមតុល្យសាច់ប្រាក់ និងធនាគារ | L&R | AC | ១៥.៩៩២.៥២៧ | ១៥.៩៩២.៥២៧ |
| ឥណទានផ្តល់ឲ្យបុគ្គលិក | L&R | AC | ៥.០៣៤.៨៦៤ | ៥.០៣៤.៨៦៤ |
| ឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | L&R | AC | ១៤១.៨៤៩ | ១៤១.៨៤៩ |

# ៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

(ក) *ស.រ.ហ.អ.ក ៩ ឧបករណ៍ហិរញ្ញវត្ថុ (ត)*

(៣) ចំណាត់ថ្នាក់ និងការវាស់វែង (ត)

តារាងខាងក្រោមសង្ខេបការធ្វើចំណាត់ថ្នាក់ និងការវាស់វែងឡើងវិញនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៨៖ (ត)

| | ចំណាត់ថ្នាក់ | | តំលៃពិតគណនេយ្យ | |
|---|---|---|---|---|
| | មាននៅក្នុង ស.គ.អ.ក ៣៩ គិតជាពាន់រៀល | ថ្មីនៅក្នុង ស.រ.ហ.អ.ក ៩ គិតជាពាន់រៀល | មាននៅក្នុង ស.គ.អ.ក ៣៩ គិតជាពាន់រៀល | ថ្មីនៅក្នុង ស.រ.ហ.អ.ក ៩ គិតជាពាន់រៀល |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីបំណុលផ្សេងៗ | OFL | AC | ១០០.៨៤៥.០៣២ | ១០០.៨៤៥.០៣២ |
| ប្រាក់កម្ចី | OFL | AC | ៣០៧.៦៣៧.៥៨៧ | ៣០៧.៦៣៧.៥៨៧ |

(ខ) *ស.រ.ហ.អ.ក ១៥ ចំណូលពីការចុះកិច្ចសន្យាជាមួយអតិថិជន*

ខាងក្រោមនេះសង្ខេបពីផលប៉ះពាល់នៃការអនុម័ត ស.រ.ហ.អ.ក ១៥ នៅលើរបាយការណ៍ហិរញ្ញវត្ថុនៃ រ.ទ.ស.ភ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ សម្រាប់ធាតុនីមួយៗដែលរងផលប៉ះពាល់៖

| | ទឹកប្រាក់ដែលមិនទាន់អនុវត្តន៍តាម ស.រ.ហ.អ.ក ១៥ គិតជាពាន់រៀល | ការកែតម្រូវ គិតជាពាន់រៀល | នៅក្នុងរបាយការណ៍ គិតជាពាន់រៀល |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| ចំណូលបង្ករពីការលក់ទឹកស្អាត | ៤៥.៥២៦.១៥៥ | (៤៥.៥២៦.១៥៥) | - |
| គណនីត្រូវទទួលពីសេវាសាងសង់ | ៥១៥.៦១៤ | (៥១៥.៦១៤) | - |
| កិច្ចសន្យាទ្រព្យសកម្ម | - | ៤៦.០៤១.៧៦៩ | ៤៦.០៤១.៧៦៩ |
| **បំណុល** | | | |
| ចំណូលមិនទាន់សម្រេច | ៣១.៣៦៧ | (៣១.៣៦៧) | - |
| ចំណូលពន្យា | ៥.២៧៨ | (៥.២៧៨) | - |
| កិច្ចសន្យាបំណុល | - | ៣៦.៦៤៥ | ៣៦.៦៤៥ |

ខាងក្រោមនេះ គឺជាស្តង់ដារគណនេយ្យ វិសោធនកម្ម និង បំណកស្រាយ ដែលត្រូវបានចេញផ្សាយរួច ប៉ុន្តែមិនទាន់ត្រូវបានអនុវត្តជាមុនដោយ រ.ទ.ស.ភ៖

| | ថ្ងៃចូលជាធរមាន |
|---|---|
| ស.រ.ហ.អ.ក ១៦ *ការជួល* | ១ មករា ២០១៩ |
| ការបកស្រាយ ២៣ *ភាពមិនច្បាស់លាស់លើការវិនិច្ឆ័យពន្ធលើប្រាក់ចំណូល* | ១ មករា ២០១៩ |
| វិសោធនកម្មលើ ស.គ.អ.ក ២៨ *ការប្រាក់រយៈពេលវែងជាមួយញាតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុន* | ១ មករា ២០១៩ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ៩ *ការទូទាត់ជាមុន ជាមួយ សំណងដែលមានភាពអវិជ្ជមាន* | ១ មករា ២០១៩ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ៣ *ការពង្រឹងប្រចាំឆ្នាំ លើស្តង់ដា ស.រ.ហ.អ.ក ខួប២០១៥ ដល់ ២០១៧* | ១ មករា ២០១៩ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១១ *ការពង្រឹងប្រចាំឆ្នាំ លើស្តង់ដា ស.រ.ហ.អ.ក ខួប២០១៥ ដល់ ២០១៧* | ១ មករា ២០១៩ |

## ៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

ខាងក្រោមនេះ គឺជាស្តង់ដារគណនេយ្យ វិសោធនកម្ម និង បំណកស្រាយ ដែលត្រូវបានចេញផ្សាយរួច ប៉ុន្តែមិនទាន់ត្រូវបានអនុវត្តជាមុនដោយ រ.ទ.ស.ភ៖ (ត)

| | ថ្ងៃចូលជាធរមាន |
|---|---|
| វិសោធនកម្មលើ ស.គ.អ.ក ១២ *ការពង្រឹងប្រចាំឆ្នាំ លើស្តង់ដា ស.រ.ហ.អ.ក ខួប២០១៥ ដល់ ២០១៧* | ១ មករា ២០១៩ |
| វិសោធនកម្មលើ ស.គ.អ.ក ២៣ *ការពង្រឹងប្រចាំឆ្នាំ លើស្តង់ដា ស.រ.ហ.អ.ក ខួប២០១៥ ដល់ ២០១៧* | ១ មករា ២០១៩ |
| វិសោធនកម្មលើ ស.គ.អ.ក ១៩ *វិសោធនកម្មផែនការ ការបន្ថយ ឫ ការទូទាត់* | ១ មករា ២០១៩ |
| វិសោធនកម្មលើ *សេចក្តីព្រាងលើក្របខណ្ឌទស្សនទានក្នុងស្តង់ដា ស.រ.ហ.អ.ក* | ១ មករា ២០២០ |
| ស.រ.ហ.អ.ក ១៧ *កិច្ចសន្យាធានារ៉ាប់រង* | ១ មករា ២០២១ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១០ និង ស.គ.អ.ក ២៨ *ការលក់ ឫការចែកចាយនៃទ្រព្យ រវាង សហគ្រិន និងញ្ញាតិសម្ព័ន្ធ ឫ ក្រុមហ៊ុនរួមទុន* | ពន្យា |

រ.ទ.ស.ភ កំពុងវិភាគលើផលប៉ះពាល់ពីការអនុវត្តស្តង់ដារគណនេយ្យវិសោធនកម្ម និង បំណកស្រាយទាំងនេះ ហេតុដូចនេះ ក្រុមប្រឹក្សាភិបាលមិនទាន់ស្ថិតក្នុងស្ថានភាពដែលកំណត់ពីផលប៉ះពាល់ដែលអាចមានទៅលើ លទ្ធផល និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅឡើយទេ។

ផលប៉ះពាល់ដែលអាចកើតមានពីការអនុវត្តស្តង់ដារគណនេយ្យ វិសោធនកម្ម និង បំណកស្រាយមានដូចខាងក្រោម៖

<u>ស.រ.ហ.អ.ក ១៦ *ការជួល*</u>

ស.រ.ហ.អ.ក ១៦ នៅកាលបរិច្ឆេទដែលមានប្រសិទ្ធភាពនឹងជំនួស ស.គ.អ.ក ១៧ ការជួល និងការបកស្រាយពាក់ព័ន្ធ ដែលបង្ហាញពីគំរូគណនេយ្យការជួលតែមួយ និងតម្រូវឱ្យអ្នកជួល ទទួលស្គាល់ទ្រព្យសកម្ម និងបំណុលសម្រាប់ការជួលទាំងអស់ដែលមានរយៈពេលលើសពី ១២ខែ លើកលែងតែទ្រព្យសម្បត្តិមូលដ្ឋានមានតម្លៃទាប។ ជាពិសេសនៅក្រោម ស.រ.ហ.អ.ក ១៦ អ្នកជួលត្រូវបានតម្រូវឱ្យទទួលស្គាល់សិទ្ធិរបស់ខ្លួនក្នុងការប្រើប្រាស់ទ្រព្យសកម្ម តំណាងឱ្យសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម និងបំណុលមូលដ្ឋានដែលបានជួល ដែលតំណាងឱ្យកាតព្វកិច្ចរបស់ខ្លួនក្នុងការទូទាត់ថ្លៃជួល។ ដូច្នេះហើយ អ្នកជួលគួរតែទទួលខុសត្រូវលើការរំលស់ទ្រព្យសម្បត្តិដែលមានការប្រើប្រាស់ និងការប្រាក់ទៅលើការទទួលខុសត្រូវលើការជួល និងបែងចែងសាច់ប្រាក់នៃបំណុលជួលទៅជាចំណែកដើមទុន និងចំណែកការប្រាក់ និងបង្ហាញនៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់។ ដូចគ្នានេះដែរសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម និងបំណុលការជួលត្រូវបានវាស់វែងដំបូងលើមូលដ្ឋានតម្លៃបច្ចុប្បន្ន។ ការវាស់វែងរួមបញ្ចូលទាំងការទូទាត់ជួលដែលមិនអាចលុបចោលបាន ហើយក៏រួមបញ្ចូលទាំងការបង់ប្រាក់ជាដំណាក់កាល ប្រសិនបើអ្នកជួលមានភាពសមហេតុផលជាក់លាក់ ក្នុងការប្រើប្រាស់ជម្រើសដើម្បីពន្យារការជួល ឬប្រើជម្រើស ដើម្បីបញ្ចប់ការជួល។ ការកត់ត្រាគណនេយ្យនេះ មានភាពខុសគ្នាយ៉ាងខ្លាំង ទៅលើគណនេយ្យរបស់អ្នកជួល ចំពោះការជួលដែលត្រូវបានចាត់ថ្នាក់ជាប្រតិបត្តិការជួល តាមស្តង់ដារមុន ស.គ.អ.ក ១៧។

ទាក់ទងទៅនឹងគណនេយ្យកររបស់ភតិសន្យាបតីនេះ ស.រ.ហ.អ.ក ១៦ អាចយោងទៅលើ គណនេយ្យរបស់ ភតិបតីនៅក្នុង ស.គ.អ.ក ១៧។ ដូច្នេះអ្នកជួល ត្រូវបន្តចាត់ថ្នាក់ភតិសន្យារបស់ខ្លួនជាភតិសន្យាប្រតិបត្តិការ ឬភតិសន្យាហិរញ្ញវត្ថុ និងបង្ហាញប្រភេទភតិសន្យាទាំងពីរនេះខុសគ្នា។

## ៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

ផលប៉ះពាល់ដែលអាចកើតមានពីការអនុវត្តស្តង់ដារគណនេយ្យ វិសោធនកម្ម និង បំណកស្រាយមានដូចខាងក្រោមៈ (ត)

<u>ការបកស្រាយ ២៣ *ភាពមិនច្បាស់លាស់លើការវិនិច្ឆ័យពន្ធលើប្រាក់ចំណូល*</u>

ការបកស្រាយ គាំទ្រតម្រូវការនៃពន្ធលើប្រាក់ចំណូល ស.គ.អ.ក ១២ ដោយផ្តល់ការណែនាំអំពីវិធីក្នុងការឆ្លុះបញ្ចាំងពីឥទ្ធិពល នៃភាពមិនប្រាកដប្រជាក្នុងគណនេយ្យសម្រាប់ពន្ធលើប្រាក់ចំណូល។

នៅក្រោមការបកស្រាយ អង្គភាពគួរកំណត់ថាតើត្រូវពិចារណាការបង់ពន្ធមិនច្បាស់លាស់នីមួយៗដាច់ដោយឡែកពីគ្នា ឬរួមគ្នា ដោយផ្អែកលើវិធីសាស្រ្តណាមួយដែលអាចទស្សន៍ទាយបានពីភាពមិនច្បាស់លាស់។ អង្គភាពក៏ត្រូវសន្មតថាអាជ្ញាធរពន្ធដារ នឹងធ្វើការត្រួតពិនិត្យមើលលើបរិមាណ ដែលខ្លួនមានសិទ្ធិពិនិត្យ និងមានចំណេះដឹងពេញលេញអំពីព័ត៌មានពាក់ព័ន្ធទាំងអស់នៅពេលធ្វើការពិនិត្យ។ ប្រសិនបើអង្គភាពយល់ថាការកំណត់របស់ខ្លួន អាជ្ញាធរពន្ធនឹងទទួលយកការបង់ពន្ធមិនច្បាស់លាស់របស់ខ្លួន នោះបន្ទាប់មកអង្គភាពគួរតែវាស់វែងពន្ធបច្ចុប្បន្ន និងពន្ធពន្យា ស្របតាមការកំណត់ពន្ធរបស់ខ្លួន។ ប្រសិនបើអង្គភាពបានកំណត់ថាវាមិនអាចទៅរួចនោះភាពមិនច្បាស់លាស់ក្នុងការកំណត់ពន្ធត្រូវបានឆ្លុះបញ្ចាំងដោយការប្រើប្រាស់ វិធីសាស្រ្តសមស្របបំផុត" ឬ "តម្លៃដែលរំពឹងទុក" ក្នុងការព្យាករណ៍ពីដំណោះស្រាយនៃភាពមិនច្បាស់លាស់។

<u>វិសោធនកម្មលើ ស.គ.អ.ក ២៨ *ការប្រាក់រយៈពេលវែងជាមួយញាតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុន*</u>

វិសោធនកម្មនេះបានបញ្ជាក់ថាក្រុមហ៊ុនមានផលប្រយោជន៍រយៈពេលវែងនៅក្នុងការចូលរួម ឬការបណ្តាក់ទុនរួម ដែលវិធីសាស្រ្តមូលធនមិនត្រូវបានអនុវត្ត ប៉ុន្តែត្រូវប្រើប្រាស់ជំនួសដោយ ស.រ.ហ.អ ៩។

<u>វិសោធនកម្មលើ ស.រ.ហ.អ.ក ៩ *ការទូទាត់ជាមុនជាមួយសំណងដែលមានភាពអវិជ្ជមាន*</u>

វិសោធនកម្មបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុ ដែលអាចទូទាត់សងដោយសំណងអវិជ្ជមានអាចត្រូវបានវាស់វែងតាមតម្លៃរំលស់ ឬតម្លៃទីផ្សារតាមរយៈប្រាក់ចំណូលផ្សេងទៀត ប្រសិនបើលក្ខខណ្ឌជាក់លាក់ត្រូវបានបំពេញជំនួសឱ្យតម្លៃទីផ្សារតាមរយៈប្រាក់ចំណេញ ឬខាត។

<u>វិសោធនកម្មលើ ស.រ.ហ.អ.ក ៣ ការពង្រឹងប្រចាំឆ្នាំ លើស្តង់ដា ស.រ.ហ.អ.ក ខួប២០១៥ ដល់ ២០១៧</u>

វិសោធនកម្មបានបោះផ្សាយក្រោមដំណើរ ការពង្រឹងប្រចាំឆ្នាំធ្វើឲ្យមានការផ្លាស់ប្តូរតិចតួចឬមិនផ្លាស់ប្តូរស្តង់ដារដែលបច្ចុប្បន្នមិនទាន់ច្បាស់លាស់។ ពួកគេបញ្ចូល ស.រ.ហ.អ.ក ៣ ដែលបញ្ជាក់ថាពេលដែលប្រតិបត្តិករួមគ្នានៃអាជីវកម្មទទួលបានការគ្រប់គ្រងលើប្រតិបត្តិការរួមគ្នាមួយ នេះជាសមិទ្ធិផលនៃការរួមបញ្ចូលអាជីវកម្ម និងផលប្រយោជន៍នៃការកាន់កាប់មូលធនមុន គួរតែត្រូវបានវាស់វែងតម្លៃទីផ្សារម្តងទៀតនៅថ្ងៃទិញលក់ *ស.រ.ហ.អ.ក ១៧ កិច្ចសន្យាធានារ៉ាប់រង*។

<u>វិសោធនកម្មលើ ស.រ.ហ.អ.ក ១១ *ការពង្រឹងប្រចាំឆ្នាំ លើស្តង់ដា ស.រ.ហ.អ.ក ខួប២០១៥ ដល់ ២០១៧*</u>

វិសោធនកម្មបានបោះផ្សាយក្រោមដំណើរ ការពង្រឹងប្រចាំឆ្នាំធ្វើឲ្យមានការផ្លាស់ប្តូរតិចតួចឬមិនផ្លាស់ប្តូរស្តង់ដារដែលបច្ចុប្បន្នមិនទាន់ច្បាស់លាស់។ ពួកគេបញ្ចូល ស.រ.ហ.អ.ក ១១ ដែលបញ្ជាក់ថា ពេលដែលភាគីបានចូលរួម ប៉ុន្តែមិនមានការចូលរួមត្រួតពិនិត្យ ការចូលរួមប្រតិបត្តិការ ដែលជាអាជីវកម្មមួយ និងក្រោយមកបានទទួលការគ្រប់គ្រងរួមគ្នាផលប្រយោជន៍នៃការកាន់កាប់មូលធនមុន គួរតែត្រូវបានវាស់វែងតម្លៃទីផ្សារម្តងទៀតនៅថ្ងៃទិញលក់របស់ខ្លួនឡើយ។

## ៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

ផលប៉ះពាល់ដែលអាចកើតមានពីការអនុវត្តស្តង់ដារគណនេយ្យ វិសោធនកម្ម និង បំណកស្រាយមានដូចខាងក្រោម៖ (ត)

<u>វិសោធនកម្មលើ ស.គ.អ.ក ១២ *ការពង្រឹងប្រចាំឆ្នាំ លើស្តង់ដា ស.រ.ហ.អ.ក ខួប២០១៥ ដល់ ២០១៧*</u>

វិសោធនកម្មបានបោះផ្សាយក្រោមដំណើរ ការពង្រឹងប្រចាំឆ្នាំធ្វើឲ្យមានការផ្លាស់ប្តូរតិចតួចឬមិនផ្លាស់ប្តូរស្តង់ដារដែលបច្ចុប្បន្នមិនទាន់ច្បាស់លាស់។ ពួកគេបញ្ចូល ស.គ.អ.ក ១២ ដែលបញ្ជាក់ថា ផលចំណេញពន្ធលើប្រាក់ចំណូលទាំងអស់នៃភាគលាភត្រូវបានទទួលស្គាល់ជាប្រចាំជាមួយប្រតិបត្តិការដែលបង្កើត ប្រាក់ចំណេញដែលអាចចែកចាយបានទាំងនៅក្នុងប្រាក់ចំនេញឬ ខាតនិងចំណូលផ្សេងៗសង្ខេបឬដោយផ្ទាល់នៅក្នុងមូលធន។

<u>វិសោធនកម្មលើ ស.គ.អ.ក ២៣ *ការពង្រឹងប្រចាំឆ្នាំ លើស្តង់ដា ស.រ.ហ.អ.ក ខួប២០១៥ ដល់ ២០១៧*</u>

វិសោធនកម្មបានបោះផ្សាយក្រោមដំណើរការពង្រឹងប្រចាំឆ្នាំធ្វើឲ្យមានការផ្លាស់ប្តូរតិចតួច ឬមិនផ្លាស់ប្តូរស្តង់ដារដែលបច្ចុប្បន្នមិនទាន់ច្បាស់លាស់។ ពួកគេបញ្ចូល ស.គ.អ.ក ២៣ ដែលបញ្ជាក់ថា ការខ្ចីមួយបានធ្វើជាពិសេសដើម្បីទទួលបានទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលនៅសល់ បន្ទាប់ពីទ្រព្យសកម្មមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលត្រូវបានត្រៀមរួចរាល់សម្រាប់ការប្រើប្រាស់ ឬ ការលក់ដែលមានបំណងនឹងក្លាយជាផ្នែកមួយនៃមូលនិធិដែលអង្គភាពខ្ចីជាទូទៅ ហើយដូច្នេះត្រូវបានរួមបញ្ចូលទាំងអស់។

<u>វិសោធនកម្មលើ ស.គ.អ.ក ១៩ *វិសោធនកម្មផែនការ ការបន្ថយ ឬ ការទូទាត់*</u>

វិសោធនកម្មបញ្ជាក់ថា៖

- វិសោធនកម្មលើការកាត់បន្ថយឬការទូទាត់ នៃផែនការអត្ថប្រយោជន៍ដែលបានកំណត់ក្រុមហ៊ុនគួរប្រើការសន្មត់តាមច្បាប់ដែលបាន ធ្វើបច្ចុប្បន្នភាពដើម្បីកំណត់តម្លៃសេវាបច្ចុប្បន្ននិងការប្រាក់សុទ្ធសម្រាប់ រយៈពេលនេះ និង
- ផលប៉ះពាល់នៃការចំណាយទ្រព្យសកម្មមិនត្រូវបានយកចិត្តទុកដាក់ នៅពេលគណនាការចំណេញ ឬ ការខាត លើការទូទាត់ណាមួយនៃផែនការ ហើយត្រូវបានដោះស្រាយដាច់ដោយឡែកពីចំណូលផ្សេងៗសង្ខេប។

<u>វិសោធនកម្មលើ *សេចក្តីព្រាងលើក្របខណ្ឌទស្សនទានក្នុងស្តង់ដា ស.រ.ហ.អ.ក*</u>

ជាមួយនឹងកែសម្រួលសេចក្តីព្រាងលើក្របខណ្ឌទស្សនទាន IASB បានចេញផ្សាយវិសោធនកម្មលើ *សេចក្តីព្រាងលើក្របខណ្ឌទស្សនទានក្នុងស្តង់ដា ស.រ.ហ.អ.ក* ដែលរួមមានវិសោធនកម្មលើ ស.រ.ហ.អ.ក ២. ៦. ១៤. ស.គ.អ.ក ១. ៨. ៣៤ . ៣៧. ៣៨. ការបកស្រាយ ១២. ១៩. ២០. និង ២២ ជាមួយនិងស្តង់ដាបកស្រាយ៣២។

<u>ស.រ.ហ.អ.ក ១៧ *កិច្ចសន្យាធានារ៉ាប់រង*</u>

ស.រ.ហ.អ.ក ១៧ ត្រូវបានជំនួសឱ្យ ស.រ.ហ.អ.ក ៤ និងតម្រូវវាស់វែងតាមតម្លៃបច្ចុប្បន្ន ដែលការប៉ាន់ស្មានត្រូវបានវាស់វែងឡើងវិញនៃការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ។

កិច្ចសន្យាត្រូវបានវាស់វែងដោយប្រើ៖

- អប្បហានៃប្រូបាប៊ីលីតេលំហូរសាច់ប្រាក់
- និយ័តកម្មហានិភ័យជាក់លាក់ និង
- ចំណេញនៃសេវាកិច្ចសន្យា ("CSM") ដែលតំណាងឱ្យកិច្ចសន្យានៃប្រាក់ចំណេញដែលមិនទាន់បានទទួលស្គាល់ ដែលត្រូវបានគេទទួលស្គាល់ថាជាប្រាក់ចំណូលក្នុងកំឡុងពេលនៃ ការធានារ៉ាប់រង។

## ៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

ផលប៉ះពាល់ដែលអាចកើតមានពីការអនុវត្តស្តង់ដារគណនេយ្យ វិសោធនកម្ម និង បំណកស្រាយមានដូចខាងក្រោមៈ (ត)

ស.រ.ហ.អ.ក ១៧ *កិច្ចសន្យាធានារ៉ាប់រង (ត)*

ស្តង់ដារអនុញ្ញាតឱ្យមានជម្រើសរវាងការទទួលស្គាល់ ការផ្លាស់ប្តូរតាមអត្រាអប្បហានៅក្នុងរបាយការណ៍ចំណូល ឬទទួលស្គាល់ដោយផ្ទាល់នៅក្នុងប្រាក់ចំណូលផ្សេងៗទៀត។ ជម្រើសនេះ គឺទំនងជាឆ្លុះបញ្ចាំងពីរបៀបដែលក្រុមហ៊ុនធានារ៉ាប់រង បកស្រាយពី ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួនក្រោម ស.រ.ហ.អ.ក ៩។

ជម្រើសម្យ៉ាងទៀត គឺវិធីសាស្រ្តបែងចែកបុព្វលាភ ត្រូវបានអនុញ្ញាតសម្រាប់បំណុលសម្រាប់ការធានារ៉ាប់រងដែលនៅសល់សម្រាប់កិច្ចសន្យារយៈពេលខ្លីដែលត្រូវបានបង្ហាញលើការធានារ៉ាប់រងមិនមានជីវិត។

ការផ្លាស់ប្តូរគំរូនៃការវាស់ស្ទង់ទូទៅដែលគេហៅថា សម្រាប់កិច្ចសន្យាមួយចំនួន "វិធីសាស្រ្តតម្លៃអថេរ" ដែលបានបង្ហាញលើការធានារ៉ាប់រងមានជីវិតដែលអ្នកធ្វើគោលនយោបាយ ចែករំលែកជាការទទួលបានមកវិញនូវតម្លៃមូលដ្ឋាន។ នៅពេលអនុវត្តវិធីកំណត់តម្លៃអថេរ ការប្រែប្រួលតម្លៃទីផ្សារនៃភាគហ៊ុនក្រុមហ៊ុននៃតម្លៃមូលដ្ឋា ត្រូវបានរួមបញ្ចូលនៅក្នុងចំណេញកម្រិតនៃកិច្ចសន្យាសេវា។ ជាលទ្ធផលក្រុមហ៊ុនធានារ៉ាប់រងដែលប្រើវិធីសាស្រ្តនេះទំនងជាមិនសូវប្រែប្រួលខ្លាំងជាងវិធីសាស្រ្តទូទៅទេ។

ច្បាប់ថ្មីនេះ នឹងប៉ះពាល់ដល់របាយការណ៍ហិរញ្ញវត្ថុ និងសូចនាករលទ្ធផលសំខាន់ៗរបស់ក្រុមហ៊ុនទាំងអស់ដែលបានចេញកិច្ចសន្យាធានារ៉ាប់រង ឬកិច្ចសន្យាវិនិយោគដែលមានលក្ខណៈពិសេសនៃការចូលរួម។

វិសោធនកម្មលើ ស.រ.ហ.អ.ក ១០ និង ស.គ.អ.ក ២៨ *ការលក់ ឬការចែកចាយនៃទ្រព្យ រវាងអ្នកវិនិយោគនិងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន*

វិសោធនកម្មបញ្ជាក់ពីវិសាលភាពនៃប្រាក់ចំណេញឬខាត ដែលត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនលក់ ឬរួមចំណែកទ្រព្យសកម្មទៅឱ្យ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុនរបស់ខ្លួន។ នៅពេលប្រតិបត្តិការពាក់ព័ន្ធនឹងអាជីវ-កម្ម ការចំណេញ ឬខាតត្រូវបានទទួលស្គាល់ពេញលេញ ផ្ទុយទៅវិញ នៅពេលដែលប្រតិបត្តិការទាក់ទងនឹង ទ្រព្យសកម្ម ដែលមិនមែន ជាអាជីវកម្មនោះការចំណេញ ឬខាតត្រូវបានទទួលស្គាល់តែទៅលើវិសាលភាព នៃផលប្រយោជន៍ វិនិយោគិនដែលមិនទាក់ទងគ្នានៅក្នុងក្រុមហ៊ុនរួមទុន ឬ ក្រុមហ៊ុនបុត្រសម្ព័ន្ធ។

## ៤. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| | មិនបានធ្វើសវនកម្ម<br>៣១ ធ្នូ ២០១៨<br>គិតជាពាន់រៀល | បានធ្វើសវនកម្មរួច<br>៣១ ធ្នូ ២០១៧<br>គិតជាពាន់រៀល |
|---|---|---|
| ***ថ្លៃដើម*** | | |
| សមតុល្យដើមឆ្នាំ | ១.៤៩៤.៧៩១.៦៣២ | ១.៣៧១.០០៤.៤៥៨ |
| ការទិញបន្ថែម | ១៤៧.២៨៣.១៧១ | ១២៨.៤០១.០៩២ |
| ការផ្ទេរទៅទ្រព្យសកម្មអរូបី | (១០.៨៥០.១១០) | (៤.១៦៣.០៤៣) |
| ការជម្រះបញ្ជី | (៩.៧០៨.៣៥៤) | (៤៥០.៨៧៥) |
| សមតុល្យចុងឆ្នាំ | ១.៦២១.៥១៦.៣៣៩ | ១.៤៩៤.៧៩១.៦៣២ |
| ***រំលស់បង្គរ*** | | |
| សមតុល្យដើមឆ្នាំ | (៣៧០.៦១៩.៤៤៩) | (៣៣៤.៥៩៤.៩១៩) |
| រំលស់ក្នុងឆ្នាំ | (៤១.៣០៧.៣១៤) | (៣៦.០២៤.៥៣០) |
| ការលក់ | ៥.៨៨៦.២៤៧ | - |
| សមតុល្យចុងឆ្នាំ | (៤០៦.០៤០.៥១៦) | (៣៧០.៦១៩.៤៤៩) |
| ***តម្លៃពិតគណនេយ្យ*** | | |
| សមតុល្យចុងឆ្នាំ | ១.២១៥.៤៧៥.៨២៣ | ១.១២៤.១៧២.១៨៣ |

ក្នុងអំឡុងពេលហិរញ្ញវត្ថុ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានធ្វើការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ និងទូទាត់ជាសាច់ប្រាក់ដូចខាងក្រោម៖

| | សម្រាប់រយៈពេល ១២ខែ គិតត្រឹមថ្ងៃទី<br>មិនបានធ្វើសវនកម្ម<br>៣១ ធ្នូ ២០១៨<br>គិតជាពាន់រៀល | <br>បានធ្វើសវនកម្មរួច<br>៣១ ធ្នូ ២០១៧<br>គិតជាពាន់រៀល |
|---|---|---|
| ការទិញបន្ថែម | ១៤៧.២៨៣.១៧១ | ១២៨.៤០១.០៩២ |
| កំណើនគណនីផ្គត់ផ្គង់ និងប្រាក់ធានាប្រតិបត្តិការ | ១៧.០៧៦.២៧១ | (១២.១៩៨.៦៥៣) |
| ការធ្វើមូលធនកម្មការប្រាក់ចំណាយលើទ្រព្យសកម្ម | (២.៧២០.១៥៩) | (៧៥៥.០១៩) |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ទូទាត់ជាសាច់ប្រាក់ | ១៦១.៦៣៩.២៨៣ | ១១៥.៤៤៧.៤២០ |

## ៥. ការវិនិយោគរយៈពេលខ្លី

ការវិនិយោគរយៈពេលខ្លីគឺជាប្រាក់បញ្ញើមានកាលកំណត់នៅគ្រឹះស្ថានហិរញ្ញវត្ថុសម្រាប់រយៈពេល៤ខែ ទៅ១២ខែ ហើយទទួលបានការប្រាក់ចាប់ពី៤,០០% ទៅ ៥,៥០% (២០១៧៖ ៤,០០% ទៅ ៥,០០%) ក្នុងមួយឆ្នាំ។

ការវិនិយោគរយៈពេលខ្លីរួមមាន ប្រាក់បញ្ញើក្នុងទឹកប្រាក់ចំនួន ៣៣,៦ ពាន់លានរៀល (២០១៧៖ ៩៦,៧ ពាន់លានរៀល)ដែលតម្កល់ទុកជាពិសេសសម្រាប់ការបង់កាតព្វកិច្ចសោធននិវត្តន៍ជូនបុគ្គលិក ដែលត្រូវចូលនិវត្តន៍ ដែលមានសិទ្ធិទទួលអត្ថប្រយោជន៍ពេលចូលនិវត្តន៍នៅក្នុងគម្រោងនេះ។

## ៦. ទុនបម្រុង

| | ដើមទុនបម្រុង គិតជាពាន់រៀល | ទុនបម្រុងស្របច្បាប់ គិតជាពាន់រៀល | ទុនបម្រុងទូទៅ គិតជាពាន់រៀល | ទុនបម្រុងសម្រាប់ធ្វើការវិនិយោគ គិតជាពាន់រៀល | សរុប គិតជាពាន់រៀល |
|---|---|---|---|---|---|
| គិតត្រឹមថ្ងៃទី១ មករា ២០១៨ | ១.៦៤៨.៤៣៥ | ២០.៧០២.០៤២ | ២០.៧០២.០៤២ | ២២១.៧៧៧.១៥៩ | ២៦៤.៨២៩.៦៧៨ |
| ផ្ទេរពីចំណេញរក្សាទុក | - | ១.៦៥៣.៣៩១ | ១.៦៥៣.៣៩១ | ១៦.៣៦៧.១៧៦ | ១៩.៦៧៣.៩៥៨ |
| គិតត្រឹមថ្ងៃទី៣១ ធ្នូ ២០១៨ (មិនបានធ្វើសវនកម្ម) | ១.៦៤៨.៤៣៥ | ២២.៣៥៥.៤៣៣ | ២២.៣៥៥.៤៣៣ | ២៣៨.១៤៤.៣៣៥ | ២៨៤.៥០៣.៦៣៦ |
| គិតត្រឹមថ្ងៃទី១ មករា ២០១៧ | ១.៦៤៨.៤៣៥ | ១៨.២៣៨.៣៨៨ | ១៨.២៣៨.៣៨៨ | ១៩១.៣៤៦.១៩៩ | ២២៩.៤៧១.៤១០ |
| ផ្ទេរពីចំណេញរក្សាទុក | - | ២.៤៦៣.៦៥៤ | ២.៤៦៣.៦៥៤ | ៣០.៤៣០.៩៦០ | ៣៥.៣៥៨.២៦៨ |
| គិតត្រឹមថ្ងៃទី៣១ ធ្នូ ២០១៧ (បានធ្វើសវនកម្ម) | ១.៦៤៨.៤៣៥ | ២០.៧០២.០៤២ | ២០.៧០២.០៤២ | ២២១.៧៧៧.១៥៩ | ២៦៤.៨២៩.៦៧៨ |

នៅថ្ងៃទី២៩ ខែមិនា ឆ្នាំ២០១៨ ក្រុមប្រឹក្សាភិបាលបានអនុម័តផ្ទេរប្រាក់ចំណេញរក្សាទុកទៅគណនីទុនបម្រុងដែលមានទឹកប្រាក់ចំនួន ១៩,៧ **ពាន់**លានរៀល។

យោងតាមលក្ខន្តិកៈរបស់ រ.ទ.ស.ភ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ ត្រង់មាត្រា ៤៤ បានចែងថា ប្រាក់ចំណេញរបស់ រ.ទ.ស.ភ បន្ទាប់ពីការកាត់កងនឹងការខាតយោងពីឆ្នាំមុន (ប្រសិនបើមាន) អាចត្រូវប្រើប្រាស់ដូចខាងក្រោម៖

- សម្រាប់ប្រាក់រង្វាន់របស់គណៈគ្រប់គ្រង និងបុគ្គលិក
- សម្រាប់ជាទុនបម្រុងផ្នែកច្បាប់ ៥%
- សម្រាប់ជាទុនបម្រុងទូទៅ ៥%
- តុល្យភាពនៅសល់សម្រាប់ទុនបម្រុងការអភិវឌ្ឍន៍

## ៧. ប្រាក់កម្ចី

| | មិនបានធ្វើសវនកម្ម ៣១ ធ្នូ ២០១៨ គិតជាពាន់រៀល | បានធ្វើសវនកម្មរួច ៣១ ធ្នូ ២០១៧ គិតជាពាន់រៀល |
|---|---|---|
| **ប្រាក់កម្ចីរយៈពេលវែង** | | |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១០៧៥ ០៣ S | ១៣.៨៤៥.២០៧ | ២៤.១៩៩.១៤៣ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - JICA | ៦១.១៣៤.០៧៥ | ៧០.៨៧២.៨៧៨ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – ធនាគារអភិវឌ្ឍន៍អាស៊ី | ២៨.៧២២.៩៥៦ | ៣០.០២៨.៥៤៦ |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១២១ ០១ F | ១០១.៥៦៣.០៦៨ | ១២៥.៨៧៤.៦៥៣ |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១៧៤ ០១ P | ៨០.៣៧០.៥៩៥ | ៧.៣១១.៦៨៣ |
| | ២៨៥.៦៣៥.៩០១ | ២៥៨.២៨៦.៩០៣ |

## ៧. ប្រាក់កម្ចី (ត)

| | មិនបានធ្វើសវនកម្ម ៣១ ធ្នូ ២០១៨ គិតជាពាន់រៀល | បានធ្វើសវនកម្មរួច ៣១ ធ្នូ ២០១៧ គិតជាពាន់រៀល |
|---|---|---|
| **ប្រាក់កម្ចីរយៈពេលខ្លី** | | |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១០៧៥ ០៣ S | ៩.២៤៧.៦២៤ | ៩.៧០៥.៣៣០ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - JICA | ១០.៨៨៣.៦៦៩ | ១១.១៣៣.១៩១ |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ៦០០០ ០១ G | - | ៦.១៣៦.២០១ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ – ធនាគារអភិវឌ្ឍន៍អាស៊ី | ២.២០០.១៨៩ | ២.២៣៩.០៨៥ |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១២១ ០១ F | ១៨.៥៥៥.២០១ | ១៩.៤៧៣.២៨៣ |
| ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១៧៤ ០១ P | ១.២៣១.៩៤៦ | ៦៦៣.៥៩៤ |
| | ៤២.១១៨.៦២៩ | ៤៩.៣៥០.៦៨៤ |
| | ៣២៧.៧៥៤.៥៣០ | ៣០៧.៦៣៧.៥៨៧ |

កាលបរិច្ឆេទផុតកំណត់របស់ប្រាក់កម្ចីនេះមានដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម ៣១ ធ្នូ ២០១៨ គិតជាពាន់រៀល | បានធ្វើសវនកម្មរួច ៣១ ធ្នូ ២០១៧ គិតជាពាន់រៀល |
|---|---|---|
| **ប្រាក់កម្ចីរយៈពេលខ្លី** | | |
| ផុតកំណត់ក្នុងរយៈពេល ១ឆ្នាំ | ៤២.១១៨.៦២៩ | ៤៩.៣៥០.៦៨៤ |
| **ប្រាក់កម្ចីរយៈពេលវែង** | | |
| ផុតកំណត់ក្នុងរយៈពេល ១ឆ្នាំ ទៅ ២ឆ្នាំ | ៣៨.៤០៦.៩៨២ | ៣៩.៨០០.២៩៤ |
| ផុតកំណត់ក្នុងរយៈពេល ២ឆ្នាំ ទៅ ៥ឆ្នាំ | ៩២.១៤៥.៦០១ | ១០៤.៨៨១.៣៩៨ |
| ផុតកំណត់ក្នុងរយៈពេល ៥ឆ្នាំ | ១៥៥.០៨៣.៣១៨ | ១១៣.៦០៥.២១១ |
| | ២៨៥.៦៣៥.៩០១ | ២៥៨.២៨៦.៩០៣ |
| | ៣២៧.៧៥៤.៥៣០ | ៣០៧.៦៣៧.៥៨៧ |

## ៨. ភាគព្វកិច្ចសោធននិវត្តន៍

ចំនួនដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុមានដូចខាងក្រោម៖

| | មិនបានធ្វើសវនកម្ម ៣១ ធ្នូ ២០១៨ គិតជាពាន់រៀល | បានធ្វើសវនកម្មរួច ៣១ ធ្នូ ២០១៧ គិតជាពាន់រៀល |
|---|---|---|
| តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ | - | ៤០.១៣៣.៧១៧ |
| តម្លៃសមស្របនៃទ្រព្យតម្កល់ | - | - |
| បំណុលដែលបានកត់ត្រានៅក្នុងគោលការណ៍ស្ថានភាពហិរញ្ញវត្ថុ | - | ៤០.១៣៣.៧១៧ |

## ៨. ភាគពួកិច្ចសោធននិវត្តន៍(ត)

បម្រែបម្រួលនៅក្នុងកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ ក្នុងអំឡុងការិយបរិច្ឆេទនេះមានដូចខាងក្រោម៖

| | សម្រាប់រយៈពេល ១២ខែ គិតត្រឹមថ្ងៃទី | |
|---|---|---|
| | មិនបានធ្វើសវនកម្ម<br>៣១ ធ្នូ ២០១៨<br>គិតជាពាន់រៀល | បានធ្វើសវនកម្មរួច<br>៣១ ធ្នូ ២០១៧<br>គិតជាពាន់រៀល |
| **សមតុល្យនៅថ្ងៃទី១ ខែមករា** | ៤០.១៣៣.៧១៧ | ៣៣.៩៨៣.៤៧៧ |
| ចំណាយលើសេវាកម្មបច្ចុប្បន្ន | ២.២៦០.០៤៦ | ១.៨០០.៦៥៧ |
| ចំណាយការប្រាក់ | ៣.១៥៥.៨៩១ | ២.៦៧១.១៦៥ |
| អត្ថប្រយោជន៍បានបង់ | (១.៣០២.៦៦៤) | (១.១៩៧.៩៥៩) |
| ខាតដែលបណ្តាលមកពីការវាយតម្លៃហានិភ័យកាតព្វកិច្ចសោធននិវត្តន៍ | ២.៩៩៣.៥៣៧ | ២.៨៦៦.៣៧៧ |
| ចំណេញពីការទូទាត់នៃកាតព្វកិច្ចសោធននិវត្តន៍ | (៣២.៩២៨.១៤៣) | - |
| ចំណាត់ថ្នាក់ឡើងវិញទៅគណនីត្រូវបង់ទៀត | (១៤.២១២.៣៨៤) | - |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ** | - | ៤០.១៣៣.៧១៧ |

ទឹកប្រាក់ដែលបានកត់ត្រាក្រោមខ្ទង់ប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ នៅក្នុងរបាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗដូចខាងក្រោម៖

| | សម្រាប់រយៈពេល ១២ខែ គិតត្រឹមថ្ងៃទី | |
|---|---|---|
| | មិនបានធ្វើសវនកម្ម<br>៣១ ធ្នូ ២០១៨<br>គិតជាពាន់រៀល | បានធ្វើសវនកម្មរួច<br>៣១ ធ្នូ ២០១៧<br>គិតជាពាន់រៀល |
| ចំណាយលើសេវាបច្ចុប្បន្ន | ២.២៦០.០៤៦ | ១.៨០០.៦៥៧ |
| ចំណាយការប្រាក់ | ៣.១៥៥.៨៩១ | ២.៦៧១.១៦៥ |
| | ៥.៤១៥.៩៣៧ | ៤.៤៧១.៨២២ |

## ៩. ជំនួយពន្យារពីរដ្ឋាភិបាល និងជំនួយផ្សេងៗ

| | ជំនួយពីរដ្ឋាភិបាល<br>គិតជាពាន់រៀល | ជំនួយពី JICA<br>គិតជាពាន់រៀល | ជំនួយផ្សេងៗ<br>គិតជាពាន់រៀល | សរុប<br>គិតជាពាន់រៀល |
|---|---|---|---|---|
| **សមតុល្យនៅថ្ងៃទី ១ ខែមករា ឆ្នាំ២០១៨** | ៤.៦៣៨.១៦២ | ២០.០៩៥.៧៤១ | ៧៥៧.០៩៨ | ២៥.៤៩១.០០១ |
| រំលស់លើទ្រព្យសកម្មអរូបី | (២២៦.៨៩៧) | (២.១០៨.៦៨០) | (២៤.៣៩៥) | (២.៣៥៩.៩៧២) |
| **សមតុល្យនៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៨** (មិនបានធ្វើសវនកម្ម) | ៤.៤១១.២៦៥ | ១៧.៩៨៧.០៦១ | ៧៣២.៧០៣ | ២៣.១៣១.០២៩ |
| **សមតុល្យនៅថ្ងៃទី ១ ខែមករា ឆ្នាំ២០១៧** | ៤.៨៦៥.០៥៩ | ២២.២០៤.៤២២ | ៧៨១.៤៩៣ | ២៧.៨៥០.៩៧៤ |
| រំលស់លើទ្រព្យសកម្មអរូបី | (២២៦.៨៩៧) | (២.១០៨.៦៨១) | (២៤.៣៩៥) | (២.៣៥៩.៩៧៣) |
| **សមតុល្យនៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៧** (បានធ្វើសវនកម្ម) | ៤.៦៣៨.១៦២ | ២០.០៩៥.៧៤១ | ៧៥៧.០៩៨ | ២៥.៤៩១.០០១ |

## ១០. គណនីពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ

| | មិនបានធ្វើសវនកម្ម ៣១ ធ្នូ ២០១៨ គិតជាពាន់រៀល | បានធ្វើសវនកម្មរួច ៣១ ធ្នូ ២០១៧ គិតជាពាន់រៀល |
|---|---|---|
| **គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ - រយៈពេលវែង** | | |
| ប្រាក់កក់របស់អតិថិជន | ៥៤.៤០៤.៧៤៦ | ៤៩.៥៥៦.៦៨១ |
| ប្រាក់ធានាប្រតិបត្តិការ | ២.៤៤៣.៨៧៧ | ១៤៣.២១៧ |
| | ៥៦.៨៤៨.៦២៣ | ៤៩.៦៩៩.៨៩៨ |
| **គណនីអ្នកផ្គត់ផ្គងពាណិជ្ជកម្ម - រយៈពេលខ្លី** | | |
| ភាគីទី៣ | ៣០.៦៦៦.៨៨៥ | ៣៤.២៣៥.៣២៦ |
| **គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ - រយៈពេលខ្លី** | | |
| បង្គរប្រាក់លើកទឹកចិត្តបុគ្គលិក | ៧.៦២៦.០១៥ | ៦.៧៣៩.៩៣៦ |
| ទឹកប្រាក់ជំពាក់សាលារាជធានីភ្នំពេញ | ១២.៦៧១.៤២៤ | ៦.៨១៤.០៥៥ |
| ទឹកប្រាក់ជំពាក់បុគ្គលិក | ១៤.២១២.៣៨៤ | - |
| ប្រាក់ធានាប្រតិបត្តិការ | ៦៧.២៨៥ | ៧៦.៨៣២ |
| ពន្ធត្រូវបង់ផ្សេងៗ | ២០៩.១៨៨ | ២៥៣.៧៤៥ |
| គណនីត្រូវបង់ផ្សេងៗ | ៤.៤៣៧.២៦២ | ២.៥៤២.៩៧៥ |
| | ៣៩.២២៣.៥៥៨ | ១៦.៤០៩.៨០៨ |
| | ៦៩.៨៩០.៤៤៣ | ៥១.១៤៥.១៣៤ |
| | ១២៦.៧៣៩.០៦៦ | ១០០.៨៤៥.០៣២ |

## ១១. ភាគលាភត្រូវបង់

នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ ក្រុមប្រឹក្សាភិបាលបានស្នើ និងអនុម័តភាគលាភសម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ដែលមានតម្លៃ ១៥៤រៀលក្នុងមួយហ៊ុន និងមានភាគលាភសរុបចំនួន ១៣,៤ពាន់លានរៀលជូនភាគហ៊ុនិក។ ភាគលាភចំនួន ២,០ពាន់លានរៀល និង ៤,៥ពាន់លានរៀលត្រូវបានទូទាត់នៅថ្ងៃទី ២៧ ខែមេសាឆ្នាំ ២០១៨ និងនៅថ្ងៃទី ១៤ ខែវិច្ឆិកាឆ្នាំ ២០១៨ ។

## ១២. ចំណូល/(ចំណាយ)ការប្រាក់

| | មិនបានធ្វើសវនកម្ម | | | |
|---|---|---|---|---|
| | សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី | | សម្រាប់រយៈពេល១២ខែ គិតត្រឹមថ្ងៃទី | |
| | ៣១ ធ្នូ ២០១៨ | ៣១ ធ្នូ ២០១៧ | ៣១ ធ្នូ ២០១៨ | ៣១ ធ្នូ ២០១៧ |
| | គិតជាពាន់រៀល | គិតជាពាន់រៀល | គិតជាពាន់រៀល | គិតជាពាន់រៀល |
| ចំណូលហិរញ្ញវត្ថុៈ | | | | |
| - ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារ (ក) | ៣២៧.៧០៩ | ៧១០.៨១១ | ១.១៧២.៩៩២ | ៤.៣៨៩.១២៥ |
| - ចំណេញសុទ្ធពីការប្តូររូបិយប័ណ្ណរបស់ប្រាក់កម្ចី | ៧.១៩០.៩៣៤ | ៣២៣.៦៣៧ | ១៥.៦៣២.៣០៤ | ១.៧៤០.១២០ |
| - ចំណូលការប្រាក់ពីឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្ត ពោធិ៍សាត់ | ១.៥៦៦ | ៣.៣២៦ | ៨.៩៥៨ | ១៥.៦៨១ |
| | ៧.៥២០.២០៩ | ១.០៣៧.៧៧៤ | ១៦.៨១៤.២៥៤ | ៦.១៤៤.៩២៦ |
| ចំណាយការប្រាក់ៈ | | | | |
| - ចំណាយការប្រាក់លើប្រាក់កម្ចី (ខ) | (២.៦២៧.៦៧៧) | (២.២៣៥.១៩០) | (១១.០១២.៦០០) | (៩.២៦៩.៨៤៤) |
| - ចំណេញសុទ្ធពីការប្តូររូបិយប័ណ្ណរបស់ប្រាក់កម្ចី | - | (១.៧៥៨.៨៧១) | (៧.៨៨៤.៣៨៦) | (២៣.៦២៦.៣១៩) |
| - ចំណាយការប្រាក់ដែលបានធ្វើមូលធនកម្មលើ ទ្រព្យសកម្មដែលមានគុណវុឌ្ឍិ | ៦៦៧.២១៨ | - | ២.៧២០.១៥៩ | ៩១.៤២៤ |
| | (១.៩៦០.៤៥៩) | (៣.៩៩៤.០៦១) | (១៦.១៧៦.៨២៧) | (៣២.៨០៤.៧៣៩) |
| | ៥.៥៥៩.៧៥០ | (២.៩៥៦.២៨៧) | ៦៣៧.៤២៧ | (២៦.៦៥៩.៨១៣) |

(ក) ចំណូលការប្រាក់គឺជាចំណូលពីគណនីប្រាក់បញ្ញើសន្សំ និងប្រាក់បញ្ញើផ្សេងៗ ដែលធ្វើនៅក្នុងធនាគារក្នុងស្រុកក្នុងអំឡុងការិយបរិច្ឆេទ។

(ខ) ចំណាយការប្រាក់គឺជាការប្រាក់លើប្រាក់កម្ចីពីAfD និងប្រាក់កម្ចីបន្តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលផ្តល់មូលនិធិដោយ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង JICA។

## ១៣. ចំណាយពន្ធលើប្រាក់ចំណេញ

នៅក្រោមច្បាប់សារពើពន្ធ រ.ទ.ស.ភ មានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញ ២០% (២០១៧: ២០%) នៃចំណេញត្រូវបង់ពន្ធ ឬ ពន្ធអប្បបរមា ១% (២០១៧: ១%)នៃផលរបរសរុប ហើយជ្រើសរើសយកមួយណាដែលខ្ពស់ជាងគេ។ វាតំណាងអោយទឹកប្រាក់អប្បបរមានៃពន្ធដែលត្រូវបង់ជូនទៅអាជ្ញាធរពន្ធដារ។ បំណុលពន្ធលើប្រាក់ចំណេញរបស់ក្រុមហ៊ុនលើសបំណុលពន្ធអប្បបរមា ដូច្នេះក្រុមហ៊ុនមិនមានកាតព្វកិច្ចបង់ពន្ធអប្បបរមាឡើយ។ ពន្ធដែលត្រូវបង់លុះត្រាតែក្រុមហ៊ុនស្ថិតនៅក្នុងស្ថានភាពខាតបង់ពន្ធ។ ក្រុមហ៊ុនមាន កាតព្វកិច្ចបង់ពន្ធនេះទោះបីជាក្រុមហ៊ុនស្ថិតក្នុងស្ថានភាពខាតក៏ដោយ។

## ១៤. ចំណេញក្នុងមួយភាគហ៊ុន

### (ក) ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន (Basic earnings per share)

ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន ត្រូវបានគណនាដោយយកប្រាក់ចំណេញរបស់ម្ចាស់ភាគហ៊ុនរបស់រ.ទ.ស.ភ ចែកនឹងចំនួនភាគហ៊ុនមធ្យម (Weighted average) ដែលបានបោះផ្សាយក្នុងការិយបរិច្ឆេទ។

## ១៤. ចំណេញក្នុងមួយភាគហ៊ុន (ត)

### (ក) ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន (Basic earnings per share) (ត)

| | សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី | | សម្រាប់រយៈពេល១២ខែ គិតត្រឹមថ្ងៃទី | |
|---|---|---|---|---|
| | មិនបានធ្វើសវនកម្ម | | មិនបានធ្វើសវនកម្ម | បានធ្វើសវនកម្មរួច |
| | ៣១ ធ្នូ ២០១៨ | ៣១ ធ្នូ ២០១៧ | ៣១ ធ្នូ ២០១៨ | ៣១ ធ្នូ ២០១៧ |
| ប្រាក់ចំណេញរបស់ភាគហ៊ុនិក (គិតជាពាន់រៀល) | ៤២.៥៨១.០៨២ | ១០.៥១៣.៧៩៦ | ៧៧.៣៩១.២៨៥ | ៣៣.០៦៧.៨២៦ |
| ចំនួនភាគហ៊ុនមធ្យម | ៨៦.៩៧៣.១៦២ | ៨៦.៩៧៣.១៦២ | ៨៦.៩៧៣.១៦២ | ៨៦.៩៧៣.១៦២ |
| ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន (គិតជារៀល) | ៤៨៩.៥៩ | ១២០.៨៩ | ៨៨៩.៨៣ | ៣៨០.២១ |

### (ខ) ចំណេញក្នុងមួយភាគហ៊ុនថយចុះ (Diluted earnings per share)

ចំណេញក្នុងមួយភាគហ៊ុនថយចុះ ត្រូវបានគណនាដោយកែប្រែចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលមាន ដោយសន្មត់ថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលទាំងអស់ទៅជាភាគហ៊ុនធម្មតា។

គិតត្រឹមដំណាច់ការិយបរិច្ឆេទនេះ រ.ទ.ស.ភ មិនមានភាគហ៊ុនដែលមានសក្តានុពលអាចផ្ទេរទៅជាភាគហ៊ុនធម្មតានោះទេ។ ដូចនេះ ចំណេញក្នុងមួយភាគហ៊ុនថយចុះគឺមានតម្លៃស្មើនឹងចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន។

## ១៥. កំណត់បង្ហាញភាគីពាក់ព័ន្ធ

### (ក) រ.ទ.ស.ភ មានប្រតិបត្តិការជាមួយនឹងសម្ព័ន្ធញាតិក្នុងការិយបរិច្ឆេទនេះដូចខាងក្រោម៖

| | សម្រាប់រយៈពេល ១២ខែ គិតត្រឹមថ្ងៃទី | |
|---|---|---|
| | មិនបានធ្វើសវនកម្ម | បានធ្វើសវនកម្មរួច |
| | ៣១ ធ្នូ ២០១៨ | ៣១ ធ្នូ ២០១៧ |
| | គិតជាពាន់រៀល | គិតជាពាន់រៀល |
| <u>ក្រុមហ៊ុនក្រោមការគ្រប់គ្រងតែមួយ</u> | | |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | |
| ការប្រាក់លើប្រាក់កម្ចី | ១០.០១៨.២៨៣ | ៩.០៥៩.២៤១ |
| រដ្ឋាករទឹកខេត្តពោធិ៍សាត់ | | |
| ការប្រាក់លើឥណទាន | ៩.៥៤៥ | ១៥.៦៨១ |

### (ខ) អត្ថប្រយោជន៍គណៈគ្រប់គ្រងសំខាន់ៗ

អត្ថប្រយោជន៍គណៈគ្រប់គ្រងសំខាន់ៗ សម្រាប់ដំណាច់ការិយបរិច្ឆេទមានដូចខាងក្រោម៖

| | សម្រាប់រយៈពេល ១២ខែ គិតត្រឹមថ្ងៃទី | |
|---|---|---|
| | មិនបានធ្វើសវនកម្ម | បានធ្វើសវនកម្មរួច |
| | ៣១ ធ្នូ ២០១៨ | ៣១ ធ្នូ ២០១៧ |
| | គិតជាពាន់រៀល | គិតជាពាន់រៀល |
| ប្រាក់បៀវត្សរ៍ និងការចំណាយផ្សេងៗ | ២.២៤៧.៨០៥ | ២.១៤៧.៧១៨ |
| អត្ថប្រយោជន៍សោធននិវត្តន៍ | ២៧.៥៦៧ | ២៦.៩៨៩ |
| | ២.២៧៥.៣៧២ | ២.១៧៤.៧០៧ |

## ១៦. គម្មវត្ថុ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

កម្មវត្ថុនៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ គឺដើម្បីបង្កើនប្រសិទ្ធភាពតម្លៃសម្រាប់ភាគហ៊ុនិក ហើយទន្ទឹមគ្នានេះក៏ដើម្បីកាត់បន្ថយសក្តានុពលនៃផលប៉ះពាល់មិនល្អ ដែលអាចកើតឡើងដោយសារការប្រែប្រួល នៃទីផ្សារហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវលើការកំណត់កម្មវត្ថុនេះ និងគោលការណ៍មូលដ្ឋាននៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ។ ហេតុនេះគណៈគ្រប់គ្រងបង្កើតគោលការណ៍លម្អិតដូចជាកម្រិតសិទ្ធិអំណាចត្រួតពិនិត្យការទទួលខុសត្រូវការកំណត់ និងវាស់វែងអត្តសញ្ញាណហានិភ័យ និងកំណត់ផលប៉ះពាល់ ដោយអនុលោមតាមកម្មវត្ថុ និងគោលការណ៍មូលដ្ឋានដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

### ក. ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់រ.ទ.ស.ភ ដោយសមភាគីមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យា។ រ.ទ.ស.ភ ប្រឈមនឹងហានិភ័យឥណទានភាគច្រើនពីការលក់ជាឥណទាន។ តាមគោលការណ៍របស់ រ.ទ.ស.ភ ត្រូវត្រួតពិនិត្យជាប្រចាំទៅលើស្ថានភាពហិរញ្ញវត្ថុ របស់សមភាគី ដើម្បីធានាថា រ.ទ.ស.ភ ប្រឈមនឹងហានិភ័យឥណទានតិចបំផុត។

ហានិភ័យឥណទានដែល រ.ទ.ស.ភ ងាយរងផលប៉ះពាល់គឺ តាមរយៈគណនីពាណិជ្ជត្រូវទទួលពីអតិថិជនតែម្នាក់។ អាយុកាលឥណទានរបស់ រ.ទ.ស.ភ មានរយៈពេល ៣ខែ ហើយ រ.ទ.ស.ភ ព្យាយាមធ្វើការគ្រប់គ្រងយ៉ាងជិតដល់លើគណនីត្រូវទទួល ដែលមិនទាន់ប្រមូលដើម្បីកាត់បន្ថយហានិភ័យឥណទានអោយទាបបំផុត។ សមតុល្យដែលហួសកំណត់ត្រូវបានពិនិត្យឡើងវិញយ៉ាងទៀងទាត់ដោយគណៈគ្រប់គ្រង។

### ខ. ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់

ហានិភ័យសាច់ប្រាក់ងាយស្រួលនិងលំហូរសាច់ប្រាក់កើតឡើងពីការគ្រប់គ្រងរបស់ រ.ទ.ស.ភ ទៅលើ មូលធនបង្វិល។ វាគឺជាហានិភ័យមួយដែល រ.ទ.ស.ភ នឹងជួបប្រទះផលលំបាកក្នុងការបំពេញនូវកាតព្វកិច្ចហិរញ្ញវត្ថុនៅពេលដែលដល់កាលកំណត់ត្រូវសង។

រ.ទ.ស.ភ គ្រប់គ្រងរយៈកាលកំណត់របស់បំណុលចាស់ៗ លំហូរសាច់ប្រាក់ពីប្រតិបត្តិការ និងភាពមានស្រាប់នៃមូលនិធិយ៉ាងសកម្ម ដើម្បីធានាបាននូវរាល់តម្រូវការប្រតិបត្តិការវិនិយោគ និងហិរញ្ញប្បទាន។ នៅក្នុងយុទ្ធសាស្ត្រនៃការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល រ.ទ.ស.ភ ធ្វើការរក្សានូវកម្រិតសាច់ប្រាក់ និងសាច់ប្រាក់សមមូលគ្រប់គ្រាន់សម្រាប់គាំទ្រ ដល់សកម្មភាពប្រតិបត្តិការរបស់ រ.ទ.ស.ភ។

### គ. ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់គឺជា ហានិភ័យដែលតម្លៃទីផ្សារ ឬលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ អាចនឹងប្រែប្រួលដោយសារតែការប្រែប្រួលរបស់អត្រាការប្រាក់ទីផ្សារ។

ការប្រឈមរបស់ រ.ទ.ស.ភ ទៅនឹងហានិភ័យអត្រាការប្រាក់ គឺទាក់ទងនឹងកម្ចី។ រ.ទ.ស.ភ គ្រប់គ្រងហានិភ័យអត្រាការប្រាក់របស់ខ្លួន ដោយត្រួតពិនិត្យយ៉ាងយកចិត្តទុកលើបំណុលទីផ្សារហើយសំខាន់ជាងនេះទៀតគឺរក្សាអោយបានការលាយឡំគ្នារបស់អត្រាថេរ និងអត្រាអថេររបស់កម្ចីដោយប្រុងប្រយ័ត្ន។ រ.ទ.ស.ភ ពុំបានប្រើប្រាស់ដេរីវេទីវឧបករណ៍ហិរញ្ញវត្ថុដើម្បីកាត់បន្ថយហានិភ័យរបស់ប្រាក់បំណុលដែលត្រូវសងនោះទេ។

## ១៧. កិច្ចសន្យាទាក់ទិននឹងការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

នៅចុងត្រីមាសនៃការិយបរិច្ឆេទហិរញ្ញវត្ថុនេះ រ.ទ.ស.ភបានជាប់កិច្ចសន្យាក្នុងការចំណាយមូលធនទៅលើទ្រព្យសកម្មខាងក្រោមៈ

| | មិនបានធ្វើសវនកម្ម<br>៣១ ធ្នូ ២០១៨<br>គិតជាពាន់រៀល | ធ្វើសវនកម្មរួច<br>៣១ ធ្នូ ២០១៧<br>គិតជាពាន់រៀល |
|---|---|---|
| ការសាងសង់រោងចក្រផលិតទឹកស្អាត | ៣៤.៩៣២.៩៤៩ | ៩៥.២៨៨.៦៦៤ |
| សេវាផ្តល់ការប្រឹក្សាយោបល់ | ៤.៧៥៤.៤៩៤ | ៥.៦៦២.២៩៦ |
| ការទិញបំពង់ដែកស្ងិត បរិក្ខារភ្ជាប់ និងបរិក្ខារផ្សេងៗ | ១៥.៥៦៧.៩៣៦ | ២៣.១២៣.៥៤០ |
| | ៥៥.២៥៥.៣៧៩ | ១២៤.០៧៤.៥០០ |

## ១៨. ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍

យោងតាមកិច្ចព្រមព្រៀងឥណទានលេខ CKH ១១៧៦ 01 S ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨ រ.ទ.ស.ភ ត្រូវបានផ្តល់ឥណទាន អតិបរមាចំនួន ២៤៧.០០០.០០០ ដុល្លារអាមេរិក ពី AfD។

## ១៩. ព្រឹត្តិការណ៍សំខាន់ៗបន្ទាប់ពីការបញ្ចប់រយៈពេលនៃរបាយការណ៍

នៅថ្ងៃទី ១០ ខែមករាឆ្នាំ ២០១៩ បន្ទាប់ពីទទួលបានការឯកភាពពីបុគ្គលិកទាំងអស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានបញ្ចប់គម្រោងប្រាក់សោធននិវត្តន៍របស់ខ្លួនដែលមានប្រសិទ្ធិភាពនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៨ ហើយនឹងផ្តល់ប្រាក់សំណងចំនួន ១៤.២ ពាន់លានរៀលទៅដល់និយោជិតទាំងអស់។ ផលចំណេញដែលកើតឡើងពីការទូទាត់នៃកាតព្វកិច្ចសោធននិវត្តន៍មានចំនួន ៣២.៩ ពាន់លានរៀល។

## ៥- ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន

ក្នុងត្រីមាសទី៤ ឆ្នាំ២០១៨ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពុំមានព័ត៌មានចាំបាច់ផ្សេងទៀតត្រូវបង្ហាញទេ។

# ហត្ថលេខារបស់អភិបាល
# របស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ថ្ងៃសុក្រ ៣រោច ខែមាឃ ឆ្នាំច
សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩
បានអាន និងឯកភាព

ហត្ថលេខា
**សឹម ណារ៉ា**
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃសុក្រ ៣រោច ខែមាឃ ឆ្នាំច
សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩
បានអាន និងឯកភាព

ហត្ថលេខា
**ស៊ឹម ស៊ីថា**
អភិបាល

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ.)**

: +៨៥៥(២៣) ៧២៤ ០៤៦

: ir@ppwsa.com.kh

: WWW.PPWSA.COM.KH

អគារលេខ ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ